• ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ

អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភិយ - ប៊ុក

ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា - សួរ - ហាយ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកអក្សរសាស្ត្រ


| | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ភិយ-ប៊ុក ក្រមការ | ឧភទមហត្ថៈគន្ធ (តមក) | ៤៨១ |
| — — | ប្រវត្តិសាស្ត្រនៃស៊ីវិល្ស៍ខ្មែរសម័យបុរាណ (តមក) | ៤៨៨ |
| ក្រុមជំនុំវប្បធម៌ | សព្ទបារាំងប្រែជាខ្មែរ ញ៉ក - ថែម រួបរួម (តមក) | ៤៩៣ |
| លោកសាង - សាភិត លេខានុការ | រឿងព្រែនភូមា (តមក) | ៥០០ |
| អ្នកឧកញ៉ាវិបុលរាជសេនា គូ - កន | រឿងសាមកុក (តមក) | ៥០៧ |
| — ទេពពិទូរ ឈឹម - ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | ៥១៤ |
| ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ | សាវតារវត្តបាយនេ ទេឃុំ ខ្វង-អ៊ូប តែង | ៥១៩ |
| លោក ផេង-ដ្រីវ សាស្ត្រាចារ្យ | បក្សីទិព្វ រឿងព្រេងប្រទេសរូម៉ានី | ៥២៧ |


## ផ្នែកសាសនា


| | | |
|---|---|---|
| លោក ភិយ - ប៊ុក ក្រមការ | ពន្ធិអាស៊ីទ្វីប (តមក) | ៥៣៣ |
| ព្រះទេពមុនី យូរ-ប៊ុណ្ណ | ពលកថា | ៥៣៦ |


## កំណត់និងប្រវត្តិការណ៍


| | | |
|---|---|---|
| ព្រះទេពសត្ថា សួរ - ហាយ | ពិធីបុណ្យស្រង់ទឹក សម្ដេចព្រះមហាសុមេធាធិបតី ជួន - ណាត (ត-ចប់) | ៥៤៥ |
| ក្រសួងធម្មការ | បញ្ជីឈ្មោះតាមឋានៈអធិការដែលតាំងថ្មី (តមក) | ៥៤៨ |


ឆ្នាំទី ២២ — លេខ ៧ ខែកក្កដា ឆ្នាំ ១៩៥០ — ដំឡៃ ១ ឆ្នាំ ១៤៥ រៀល
1950

LIBRARY
M.814

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

# TABLE DES MATIÈRES

## Partie littéraire:


| | | page |
|---|---|---|
| M. Ray-Buc Kramakar (I.B.) | Paroles de GANDHI (suite) ........... | 481 |
| — id — | Histoire: Ancienne civilisation khmère de M. George COEDES (traduction) (suite) ......... ........ .... | 488 |
| Commission Culturelle | Mots traduits par la commission Culturelle et recueillis par M. Nhok-Thèm (suite) ................ | 493 |
| M. Sarg-Savath, Ministère des Finances | Contes birmans (suite)....... ..... | 500 |
| Neak Oknha Vibularajaséna Nou-Kân | Histoire de SAMKOK (suite)........ | 507 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite)................ ........ | 514 |
| Commission des Mœurs et Coutumes | Notice historique sur la pagode de Banoi (Angkanh-Takéo) par Mékhum Duong-Ouch ........ .. ......... | 519 |
| M. Pheng-Chrieu, Professeur au Collège des jeunes filles | Contes roumains: L'oiseau de paradis. | 527 |


## Partie religieuse:


| | | |
|---|---|---|
| M. Ray-Buc Kramakar | Lumière de l'Asie (suite) ......... | 533 |
| Préah Debamuni You-Ponn | Balakatha ............ ........ | 536 |


## Notes et chroniques


| | | |
|---|---|---|
| Brah Debasattha So-Hay | Cérémonie d'aspersion d'eau lustrale de Samdach Préah Moha Sumedhathipadi Chuon-Nath, Chef de Secte Mohanikay ........................ | 545 |
| Ministère des Cultes | Nomination des nouveaux Chau-Adhikar (suite) .............. . | 558 |

## លោកវ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តមក)

---

៣៦ — មធ្យោបាយដ៏បរិសុទ្ធដើម្បីនឹងរកយុត្តិធម៌ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្ត គេមិនត្រូវស្រាវជ្រាវរកបុព្វហេតុនៃរឿងរ៉ាវនេះទេ អ្នកដែលបានប្រព្រឹត្តធ្វើឃាតកម្ម ទោះបីជាជាតិសិក្ខ (sikhs) ឬប៉ាថាំង (Pathans) ឬឥណ្ឌូ ជាអ្នកស្នេហាជាតិ ទណ្ឌកម្មដែលធ្វើចំពោះអ្នកទាំងនោះ មិនមែនធ្វើឲ្យបុគ្គលដែលទទួលមរណភាពទៅហើយ មានជីវិតរស់ឡើងវិញបាន ។ ខ្ញុំចង់សូមអ្នកដែលរងនូវសេចក្តីសោកចំពោះបុគ្គលដែលអនិច្ចកម្មទៅនោះ ឲ្យមានចិត្តសន្តោសប្រោសប្រណីដល់អ្នកដែលបានធ្វើមនុស្សឃាត, ធ្វើបែបនេះមិនមែនយល់ថា អ្នកដែលទទួលនូវសេចក្តីសោកជាបុគ្គលទុព្វលភាព (ខ្ញុំដឹងថាអ្នកទាំងនោះមានមធ្យោបាយជាច្រើនស្ថាន ដើម្បីនឹងធ្វើទណ្ឌកម្មដល់អ្នកប្រព្រឹត្តល្មើស) តែដោយហេតុថា ពលភាពអ្នករងសេចក្តីសោកនោះគ្មានខ័ណ្ឌព្រំដែនទេ ។ អ្នកណាមួយដឹងខ្លួនដោយខ្លួនឯងថា ខ្លួនមានពលភាព អ្នកនោះតែងមានចិត្តខន្តីអត់ធននូវទោសនោះបាន ។

[illegible]ខ្ញុំជាអ្នកស្នេហាជាតិព្រោះខ្ញុំជាជាតិមនុស្ស ហើយខ្ញុំមានសភាព និងចរិយារបស់មនុស្ស ខ្ញុំមិនបានធ្វើទុក្ខលំបាក ដល់ប្រទេសអង់គ្លែស ឬប្រទេសអាល្លឺម៉ាញ ដោយខ្ញុំបានបំរើប្រទេសឥណ្ឌានោះទេ, លទ្ធិក្រ-ពត្តិនិយម គ្មានសន្ទិតជាប់នៅក្នុងសន្តានខ្ញុំ តាមយោបល់របស់ខ្ញុំចំពោះ ជីវភាពលោក, សីលធម៌នៃអ្នកស្នេហាជាតិ (Patriote) មិនខុសគ្នាពី សីលធម៌នៃពួកបេត្តយ្យបុគ្គល (patriarche) ។

**មនុស្សធម៌ តទល់នឹងសភាពស្នេហាជាតិ**
**( ១៦-៣-១៩២១ )**

៣៧ – កុំឲ្យប្រើកំឡាំងយើងហួសប្រមាណក្នុងការណ៍ដែលគិតពី បញ្ហាប្រជាជាតិ ព្រមទាំងមធ្យោបាយក្នុងបញ្ហានេះ បុគ្គលអាពាធដែល បរិភោគនូវឱសថច្រើនប្រការតែម្ដង មុខជាអន្តរាយដល់ជីវិតមិនខាន ។

**រូបភាពនៃសភាកុងគ្រែស**
**(៣០ - ៣ - ១៩២១)**

៣៨- ប្រជាជាតិត្រូវមានទង់ជ័យជាដួងវិញ្ញាណរបស់ជាតិ, មនុស្ស ជាច្រើនសែននាក់បានបូជាជីវិតព្រោះតែទង់ជ័យនេះ; ទង់ជ័យតាំងផ្ដើម ឡើងដោយលទ្ធិពាហិរសាសនាមួយយ៉ាង ដែលយើងមិនត្រូវបំផ្លាញ ឲ្យសាបសូន្យ, រូបតំនូវសាមគ្គីសាក់ (Union Jack) បើគេបានបង្ហាញឲ្យ ឃើញជាក់ស្ដែងចំពោះមុខ អាចនាំឲ្យជាតិអង់គ្លេសមានមនោសញ្ចេតនាដ៏ ខ្លាំងក្លាមិនអាចនឹងកំណត់នូវពលភាពបាន, រូបតំនូវ ស្ដារអង់ស្ទ្រីប

(Stars and Stripes) ដែលជាតិអាមេរិកាំងបានយកទៅរចនាដាក់លើទង់ជ័យ ដែលប្រែថា "លោកទាំងមូល", តារានិងរង្វង់ព្រះចន្ទខាងនោះ នាំឲ្យជាតិឥស្លាមមានចិត្តក្លាហានពន់ពេក, ពួកជាតិឥណ្ឌូមហាម័ត ក្រៅពីនេះ ស៊ីហ្វ និងជាតិឯទៀត ដែលបានយកប្រទេសឥណ្ឌាជាមាតុភូមិ យើងត្រូវការឲ្យមានទង់ជ័យមួយជាប្រធានរបស់ជាតិ ដែលយើងត្រូវការបម្រុងខ្លួនស៊ូស្លាប់ព្រោះទង់ជ័យនេះ ។

ទង់ជ័យប្រជាជាតិ

(១៣-៤-១៩២១)

៣៩- បើទុកជាបេះប្រើវិធីយ៉ាងណាក៏ដោយ វឌ្ឍនធម៌នៃប្រជាជាតិមិនមែនមកពីមនុស្សម្នាក់ៗទេ ឬមកពីក្រុមណាមួយៗទេ ។

... គេស្គាល់ដើមឈើដោយឃើញផ្លែវា ។

ខេយបុះអ័ក្ង

(២០-៦-១៩២១)

៤០ - ប្រទេសណាមិនអាចទៅជាប្រជាជាតិមួយបាន បើនៅប្រទេសនោះមានតែពួកវិប្បយុត្តបុគ្គល ។

ការសិក្សាអង់គ្លេស

(២៧-៦-២១)

៤១ - សភាពបែកសាមគ្គីជាទោសនាំទៅកាន់សេចក្ដីវិនាសជាប្រាកដ ។

សាមគ្គីភាពរវាងជាតិឥណ្ឌូនិងមហាម័ត

(១១-៥-១៩២១)

៤២– រឹងសេចក្តីក្រោយហើយទុកចិត្តខ្លួនឯង នេះជាគុណសម្បត្តិពលភាពរបស់អាត្មន ។

ផាតិនណ្ហកុំប្រមាទ
(១៨-៥-២១)

៤៣– ការពិសោធន៍ បានបង្ហាញខ្ញុំឲ្យឃើញថា ការសិក្សាអក្សរសាស្ត្រ មិនអាចធ្វើឲ្យចំរើននូវសីលធម៌ សម្បត្តិបន្ថែមគឺគ្មាន ហើយការអប់រំនូវអក្សរសាស្ត្រ មិនមានហេតុទាក់ទងក្នុងការអប់រំនូវចរិយា ។

. . . រដ្ឋាភិបាលដែលនឹងគាំងក្រែតត្យានុភាពបាន ដោយការអាស្រ័យប្រជារាស្ត្ររួមយល់ព្រមប្រតិបត្តិតាម ។

. . . ពួកយុវជនជាវិសង្ឃឹមរបស់ប្រជាជាតិ ។

. . . ត្រូវតែលះបង់ពាក្យដែលមិនប្រកបដោយសច្ចៈ ទើបជាអ្នកទទួលពាក្យសត្យបាន ។

. . . សាសនាក្នុងលោកសំដែងថា នៅក្នុងខ្លួនយើងមានកំឡាំងពីរ ហើយសេចក្តីប្រែប្រួលរបស់មនុស្ស គឺសម្រេចថាព្រមទទួល ឬ មិនព្រមទទួល នូវពាក្យប្រះឃាំងនោះ ជានិរន្តរកាល ។

. . . ការណ៍ដែលមិនព្រមសមាគមជាមួយនឹងកិច្ចការ ជាវិធីមួយដែលប្រជាជាតិត្រូវប្រើ ដើម្បីឲ្យរដ្ឋាភិបាលដឹងខ្លួនជាមុនថា ប្រជាជាតិមិនព្រមសុខចិត្តនៅក្រោមអធិបតេយ្យឡើយ ។ សភាពបារក្គនៃពួកកវី
(១ ៦-១៩២១)

៤៤ – វត្ថុដែលរដ្ឋាភិបាលស្វែងរកក្នុងបរិយោសានកាល ដោយប្រើកំឡាំងអាវុធ, វត្ថុនោះត្រូវស្វែងរកដោយប្រើកំឡាំងមេត្តាចិត្ត ។

គណៈកម្មាធិការកម្មិកភាពនិងវិធីខៃផែនការ
(៦. ៣- ១៩២១)

៤៥ – ខ្ញុំបានបង្ហាញឲ្យឃើញថា គេអាចស្អប់នូវអំពើទុច្ចរិតដែលបងប្អូនណាមួយប្រព្រឹត្ត តែគេមិនអាចនឹងស្អប់នូវបុគ្គល ដែលប្រព្រឹត្តទុច្ចរិតនោះឡើយ ។

... ខ្ញុំបានរកឃើញថា មនុស្សមានគុណធម៌ខ្ពង់ខ្ពស់ ប្រសើរជាងវិធីដែលខ្លួនបានរៀបចំអង្គការ ។

... អ្នកឯងនឹងឃើញជាទាសានៃវិធីការដែលធ្វើ ។

ចំពោះជាតិអង់គ្លេសដែលនៅប្រទេសឥណ្ឌា
(១៣ - ៣ ១៩២១)

៤៦ – យើងមានវត្ថុពីរបែបដែលជាប្រធានក្នុងចិត្តគ្រប់រូប គឺសេចក្តីស្នេហាចំពោះមាតុភូមិ នឹងសេចក្តីព្យាយាមដោយមិនគិតនឿយហត់ ដើម្បីនឹងឲ្យបានស្វ័យភាព ។

អបលសេទា
(១៦-៣-១៩២១)

៤៧ – ត្រូវតែនារីមានសិទ្ធិបោះឆ្នោត, គួររក្សាសមភាពចំពោះសិទ្ធិនារីនិងបុរស ។

... ច្បាប់លទ្ធិអហិង្សាប្រកាសប្រគល់ឲ្យនារីមានសិទ្ធិស្មើគ្នានិងបុរស ។

... ត្រូវតែនារីកុំយល់ថាខ្លួនគ្រាន់តែជាវត្ថុសម្រាប់ឲ្យបុរសត្រេកត្រអាលកំសាន្តចិត្តប៉ុណ្ណោះ ។

សិទ្ធិនៃនារី
(០៤-៣-១៩៦១)

៤៨ – បើតាមយោបល់ខ្ញុំថា ក្រៅពីសម្ពន្ធកិច្ចនៃការសិក្សាចំពោះរដ្ឋាភិបាលទុច្ចរិតចេញ នៅមានរបៀបការសិក្សាក្នុងសម័យបច្ចុប្បន្នជាសភាពលាមកមួយ ដោយវិចារណញ្ញាណ ៣ យ៉ាង គឺ:

១ – របៀបការសិក្សានេះ ពឹងផ្អែកទៅលើវប្បធម៌ របស់បរជាតិជាគោល ដោយការលុបចោលស្ទើរតែទាំងអស់នូវវប្បធម៌នៃជាតិរបស់ខ្លួន ។

២ – របៀបការសិក្សានេះ លះបង់ចោលនូវវប្បធម៌ខាងផ្លូវចិត្ត ហើយនឹងវប្បធម៌ខាងហត្ថកម្ម ច្រើនអប់រំចំពោះវប្បធម៌ខាងផ្លូវប្រាជ្ញា ។

៣ – មិនត្រូវយល់ថា ការសិក្សាប្រាកដនោះព្រោះអប់រំប្រើភាសាជនបរទេសទេ ។

បើខ្ញុំធ្វើគ្រូ ខ្ញុំនឹងបំផ្លាញនូវសៀវភៅតម្រាក្បួនខ្នាតគម្ពីរដែលក្មេងរៀនសូត្រសព្វថ្ងៃនេះចេញ ហើយខ្ញុំចាត់របៀបអង្គការតែងសៀវភៅបែបថ្មី គឺ: សរសេរអំពីរឿងដំណាលនៃត្រកូល ឬគ្រួសារ នឹងការទាក់ទងក្នុងគ្រួសារនេះ ដើម្បីនឹងបង្ហាញឲ្យក្មេងរៀន ព្រមទាំងអប់រំចិត្តគំនិតអធ្យាស្រ័យទៅតាមមជ្ឈដ្ឋានដែលខ្លួននៅ ។

... ពួកយុវជនត្រូវទទួលការសិក្សាណាដែលមានការអប់រំហត្ថកម្មជាប្រធាន ។

... មិនមានវត្ថុអ្វីដែលនាំឲ្យខូចសីលធម៌ប្រជាជាតិដូចការប្រមាថនូវការហត្ថកម្មឡើយ ។

... ចំណេះចេញពីបណ្ឌិតសភា តែមិនបានយកមកអប់រំខាងវិធីប្រតិបត្តិ ប្រៀបដូចសាកសពដែលគេអប់ដោយគ្រឿងក្រអូប គួរជាទីទស្សនិយភាពពន់ពេក តែមិនអាចរបនាអ្នកដែលមើលឲ្យមានគំនិតថ្មីឬមានចិត្តប្រែឡើងទៅកាន់អរិយធម៌ដ្ឋាន, លទ្ធិរបស់ខ្ញុំ ហាមខ្ញុំ កុំឲ្យបន្ទោកឬមើលងាយវប្បធម៌អ្នកដទៃ តែបង្ខំខ្ញុំឲ្យប្រតិបត្តិតាមវប្បធម៌ដែលខ្ញុំបានអប់រំមក ឲ្យធ្វើវប្បធម៌នោះជាកល្យាណមិត្ត មានដួងវិញ្ញាណតែមួយឯកឯង, បើខ្ញុំមិនប្រព្រឹត្តតាមសភាពនេះទេ គេនឹងទុកខ្ញុំជានាយពេជ្ឈឃាតនៃពួកពលរដ្ឋស៊ីវិល ។

ការសិក្សាប្រជាជាតិ
(១-៩-១៩២១)

(មានត)

កុំបាប់គេះបាប់គោះមិនឆ្គោះត្រង់ណា,
បើធ្វើអ្វីគប្បីធ្វើឲ្យហើយទើបមានសួស្តី

# ប្រវត្តិសាស្ត្រនៃស៊ីវិល្យខ្មែរបុរាណ

## លោករ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ក្រសួងក្រមរាជការសំខាន់ៗ ច្រើនប្រគល់ឲ្យពួកវណ្ណព្រាហ្មណ៍, តំណែងទាំងប៉ុន្មាន គឺក្រមសង្ឃការីពិសេសផ្ទាល់ព្រះអង្គ (Chapelain du Roi) ១ ព្រាហ្មណ៍ដែលសូត្រធម៌ថ្វាយព្រះរាជសព្វសាធុការពរដល់ព្រះវិញ្ញាណមហាក្សត្រដែលប្រតិស្ឋានរូបជាព្រះមួយ (Officiant du Dieu Roi) ១ សាស្ត្រាចារ្យព្រះរាជឧបាធ្យាយ (Précepteur) ១ ត្រូវទុកឲ្យពពួកវង្សត្រកូលដ៏ឧត្តមកាន់កាប់តទៅ ៗ មុខការទាំងនេះ ត្រូវផ្ទេរទៅតាមក្រសែខាងស្ត្រី, ប្អូនពៅខាងបងស្រី ឬបុត្រនៃបងស្រីទទួលមុខការទាំងនេះ តអំពីបងប្រុសច្បងឬឪពុកមា ៗ ត្រកូលព្រាហ្មណ៍អាចធ្វើសមរសបានជាមួយនឹងត្រកូលក្សត្រ, សមរសបែបនេះមានច្រើន ព្រោះវណ្ណៈក្សត្រនឹងវណ្ណៈព្រាហ្មណ៍ទាំងពីរនេះជាវណ្ណៈឧត្តុង្គឧត្តមជាងប្រជាករ ហើយមានឋានៈក្រៅដោយឡែក ដែលគេទុកជាក្រុម ១ ហៅថា ក្រុមបណ្ឌិត ចំពោះស៊ីវិល្យហិណ្ឌូទាំងមូល; តែកិច្ចការរៀបចំរបៀបវណ្ណៈនេះ ចំពោះបណ្តាជាតិ ទៅជាសភាពអនាធិបតេយ្យដែលមានលក្ខណៈផ្សេងពីប្រជាកស្តែងទៀត ៗ យើងបានឃើញជាញឹកញយនូវឈ្មោះខាងក្សត្រ ក្រុមព្រះរាជវង្សានុវង្ស នឹងក្រុមព្រះសង្ឃ ៗ

តាមសិលាចារឹកបង្ហាញឲ្យឃើញថា មានពូជត្រកូលពួកមន្ត្រីជាច្រើន ៗ យើងអាចយល់ថាក្នុងពេលនោះព្រះរាជរដ្ឋាភិបាល បានរៀបចំមាំមួននូវរដ្ឋមន្ត្រី, មេទ័ព, ទីប្រឹក្សា, អធិការ, ចៅហ្វាយខេត្ត, -ស្រុក-ភូមិ, ប្រជារាស្ត្រ, នាយឃ្លាំងផ្សេង ៗ, នាយបាតកការខាងពួកគូលីធ្វើការថ្ងៃ, នឹងមន្ត្រីឯទៀតជាច្រើនដែលមានឋានន្តរស័ក្តិមិនសូវច្បាស់លាស់ ហើយតែញែកជាបួនថ្នាក់ដែលមានលក្ខណៈមិនប្រាកដ ៗ បើដោយស្មាន, ប្រហែលត្រូវគ្នានឹងព្រះរាជវង្សានុវង្សបួនយ៉ាងនៃប្រទេសកម្ពុជាទំនើប គឺ: ព្រះមហាក្សត្រិយ៍ ១ ព្រះរាជតាយាទ ១ ព្រះរាជតាយាទបន្ទាប់តមក ១ នឹងព្រះអគ្គមហេសី ១ ។

មន្ត្រីទាំងអស់នោះត្រូវនៅក្រោមព្រះបញ្ជាព្រះមហាក្សត្រិយ៍ដោយធ្វើសច្ចាប្រណិធាន ដូចមាននៅប្រទេសកម្ពុជានឹងលាវ ដែលមានពិធីធ្វើសច្ចាប្រណិធាន ជាព្រះរាជពិធីមួយធំសព្វឆ្នាំ ។ សិលាចារឹកដែលបានឆ្លាក់នៅទ្វារនៃព្រះបរមរាជវាំងអង្គរធំ មានពោលអំពីរឿងពិធីធ្វើសច្ចាប្រណិធាន ដែលលោកអធិការក្រុមព្រះបរមរាជវាំងទាំងបួនថ្នាក់ បានថ្វាយពី ព.ស. ១០១១ ដូចមានខសំខាន់ៗ ខាងក្រោម:

"យើងមិនបានសរសើរព្រះរាជកិត្តិយសព្រះមហាក្សត្រិយ៍ណា ក្រៅពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូងរបស់យើង, យើងមិនទទឹងទាស់នឹងព្រះរាជបំណង ហើយយើងមិនបានចូលដៃនឹងពួកបច្ចាមិត្តរបស់ព្រះ

អង្គ, យើងមិនបានប្រព្រឹត្តនូវអំពើដែលនាំឲ្យវិនាសដល់ព្រះអង្គ យើងខំព្យាយាមប្រព្រឹត្តនូវអំពើដែលនាំផលនៃអភិវឌ្ឍន៍និងកតវេទីចំពោះព្រះករុណា; បើមានសង្គ្រាម យើងខំព្យាយាមចូលតស៊ូដោយពលភាពរបស់ចិត្ត ព្រមទាំងមិនគិតដល់ជីវិតសោះឡើយ; ដោយអភិវឌ្ឍន៍ចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង, យើងមិនរត់ចេញឲ្យឆ្ងាយពីទីសមរភូមិ, បើមិនមានចម្បាំងទេ, យើងស៊ូស្លាប់ដោយសារធ្វើឃាតកម្មខ្លួនឯងឬដោយមរណភាព; យើងសូមឲ្យបានរង្វាន់ ឬកិត្តិយសចំពោះបុគ្គលដែលមានចិត្តត្រង់និងទៅហ្វាយនាយ; យើងនឹងធ្វើការថ្វាយព្រះមហាក្សត្រិយ៍ទាល់តែខ្លួនមរណភាព បើសិនណាជាត្រូវស្លាប់ក្នុងពេលដែលធ្វើការនោះ យើងនឹងបំពេញករណីយកិច្ចចំពោះព្រះមហាក្សត្រិយ៍ឥតមានរួញរាសោះឡើយ; បើមានកិច្ចការអ្វីដែលព្រះករុណាចាត់យើងទៅឆ្ងាយដោយមានព្រឹត្តិការ ដែលព្រះអង្គបានប្រាប់ជាមុន, យើងត្រូវខំប្រឹងប្រែងរករឿងនោះដោយពិស្ដារ ។ បើបណ្ដាយើងទាំងអស់គ្នា មានអ្នកណាមិនព្រមធ្វើតាមសច្ចាប្រណិធាននោះ យើងសូមឲ្យព្រះមហាក្សត្រិយ៍ដែលសោយរាជ្យសម្បត្តិតទៅអនាគតធ្វើព្រះរាជទណ្ឌកម្មដល់អ្នកនោះ បើមានអ្នកណាក្បត់ព្រះអង្គមិនព្រមធ្វើតាមពាក្យសច្ចាប្រណិធាន សូមឲ្យអ្នកនោះទៅរងទុក្ខលំបាកវេទនានៅមហានរកទាំងសាមសិបពីរ ឲ្យបានយូរអង្វែងស្មើនឹងសេចក្ដីស្ថិតនៅនៃព្រះអាទិត្យនិងព្រះចន្ទ; បើបានប្រតិបត្តិតាមពាក្យសច្ចា

ប្រណិធាន សូមឲ្យព្រះមហាក្សត្រិយ៍មានព្រះរាជតម្រាស់ថា ដូចនិយ-
ដ្ឋានត្រប់ទឹកទន្លេក្នុងប្រទេស ត្រូវចាត់ឲ្យវង្សត្រកូលយើងមើលថែរ៉ា
កិត្តិយសនៃបុគ្គលដែលចិត្តត្រង់ ចំពោះព្រះមហាក្សត្រ យើងសូមឲ្យបាន
សម្រេចតាប់ដើមអំពីលោកនេះ រហូតដល់បរលោក ។

ក្នុងសម័យបច្ចុប្បន្ន, ពិធីធ្វើសច្ចាប្រណិធាននៅតំពេញត្រូវបរិភោគ
ទឹកមួយពែង ដែលគេជ្រលក់ពាងមួយគ្រាំដោយគ្រឿងសស្ត្រាវុធយុទ្ធភ័ណ្ឌ
ក្នុងពេលនោះត្រូវផ្តុងចិត្តអធិដ្ឋានតាមទំនៀមថា: បើមិនប្រព្រឹត្តទៅតាម
ពាក្យពោលហើយ សូមឲ្យគ្រឿងសស្ត្រាវុធប្រហារ; ដោយយល់
ឃើញថាពលកាពនៃគ្រឿងសស្ត្រាវុធជ្រាបចូលទៅក្នុងហទយវត្ថុ ។ ក្នុង
សម័យអង្គរ ការធ្វើសច្ចាប្រណិធានជាកិច្ចពិតប្រាកដ គេយកលោហិត
ជាប្រធានរូបមន្តចំពោះសច្ចាប្រណិធានគឺ "នេះជាសេចក្តីអធិដ្ឋាន
ដែលយើងបានពោលក្នុងឱកាស ដែលយើងបានតាក់ដៃឲ្យចេញឈាម
ហើយដែលយើងបូជាជីវិត ចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង",
ទម្លាប់នោះមានធ្វើរៀងរៀបមកដល់សព្វថ្ងៃ ។ នៅប្រទេសកម្ពុជា
ចំពោះពួកចោរលួច, ប្លន់, ការធ្វើសច្ចាប្រណិធាន គឺត្រូវធ្វើសម្ពន្ធកិច្ច
ដោយបរិភោគស្រាមួយពែង ដែលគេបានសម្រក់លោហិតពីសរសៃកដៃ
គឺជាទំនៀមទម្លាប់ដូចគ្នា ដែលគេបានបារិតពាក្យសច្ចាប្រណិធានទាំង
ព្រះបរមរាជវាំង ។

រូបមន្តនៃពាក្យសច្ចាប្រណិធានមានខាងក្រោមបញ្ជីកឈ្មោះមន្ត្រី ដែលត្រូវប្រកាសពាក្យនេះចំពោះឈ្មោះនីមួយ ៗ មានចុះឈ្មោះកូម៉ិកាគ ។ បានជាក្នុងសតវត្សទី ១១ គេមានឃើញបញ្ជីកយនាមកូមិកាគនៅប្រទេសកម្ពុជា ដែលមកដល់ចុងសតវត្ស ១៣, ក្នុងពេលដែលមហាពជមង្គល បានបាត់គណៈប្រតិកូមក មានដល់ ៩០ ខេត្ត ៗ គណៈប្រតិកូនេះ បានកត់ត្រាអំពីរបៀបរដ្ឋាភិបាលក្នុងពេលនោះ ដែលគេហៅថា អភិជនសិទ្ធិជាអនាធិបតេយ្យ (Olifarchie aristocratique) ពួកគណៈប្រតិកូនោះ បានឲ្យដំណឹងថា " ដូនកាលគេជ្រើសតាំងព្រះអង្គម្ចាស់ឲ្យទទួលមុខការរាជការផ្សេងៗ, ចំពោះមន្ត្រីធំ - តូច បើចង់បានការអ្វីត្រូវយកកូនស្រីទៅថ្វាយព្រះមហាក្សត្រិយ៍ " ។ រូបមន្តបែបនេះគេបានយកមកអនុវត្តន៍នៅប្រទេសកម្ពុជា និងប្រទេសសៀមខាងដើមសតវត្សនេះ ៗ តាមដំណឹងចិននេះថាបានកត់ត្រាពីគ្រឿងឥស្សរិយយស នៃនាហ្មឺនសព្វមុខមន្ត្រី គឺអង្រឹងមានឈើសែង មាសឬប្រាក់, សប្បធនមានដៃនដោយមាស ឬប្រាក់ តាមឋានន្តរស័ក្តិមុខងារ ។

( មានត )

មិនអាចរកសេចក្ដីសុខឃើញទេ

បើគ្មានវិជ្ជា ប្ញរមើលសត្វបរើ !

# សព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តមក)

---

Centralisation = មជ្ឈការ

Décentralisation = វិមជ្ឈការ

Le secrétaire archiviste = លេខាធិការកាន់ឯកសារ

Le Chef du Service des Recettes = នាយក្រុមប្រាក់ចំណូល

Le Chef du Service des Dépenses = នាយក្រុមប្រាក់ចំណាយ

Le Chef du Service des Budgets = នាយក្រុមថវិកា

Confidentiel = អាថ៌កំបាំង

Pour copie conforme = ចំឡងត្រឹមត្រូវហើយ

Pour ampliation = សម្រាប់ចំឡងចែក

Vu pour attache = បានឃើញដើម្បីទទួលជំន

En communication = ដើម្បីជាគំណាន់ដល់

Marge = រឹមដើម (ទំព័រសៀវភៅ)

(25—2—49)

Parité de solde = (ថ្នាក់) បៀវត្សស្មើគ្នា

Diplôme d'études primaires = សញ្ញាប័ត្របឋមសិក្សា

Brevet Elémentaire = ប្រកាសនីយប័ត្រជាន់ដំបូង

Baccalauréat = មធ្យមសិក្សាប័ត្រ

Licence = បរិញ្ញាប័ត្រ

Agrégation = មហាបរិញ្ញាប័ត្រ

Doctorat = ថ្នាក់បណ្ឌិត្យ

Valider = ធានការ

Affiliation = ការចូលរួម

Catégorie = ថ្នាក់, ប្រភេទ

Brigadier = អ្នកត្រួត

Chef de poste = នាយតំបន់

Poste de contrôle = តំបន់ត្រួតត្រា

Chef de contrôle = នាយត្រួតត្រា

Chef de section = នាយផ្នែក

Contrôleur = អ្នកត្រួតត្រា

Receveur = បដិគ្គាហក, អ្នកទទួល

(Le 15 — 3 — 49

Nimbus = ជលធរ

Cumulus = ក្នំទឹក

Stratus = អន្តលិក្ខ, អន្តរិក្ស (ដើរក្លាយ)

Cirrus = ពពកស្រកានាគ

(Le 18 – 3 – 49)

Thermomètre = ឧណ្ហមាត្រ

Degré = កម្រិត

Fiche = សលាកប័ត

Sens Unique = ឯកទិស

Température = សីតុណ្ហភាព

Travail = ការងារ

(Le 22 – 3 – 49)

Compromis = ការសម្រប

Fête = មហោស្រព, បុណ្យ

Cérémonie = ពិធី

Adjudication =
Appel d'offres = } ការដេញថ្លៃ

Fête nationale = បុណ្យជាតិ

Fête royale = ព្រះរាជពិធី

Attributs (de l'indépendance) = វិសេសលក្ខណ៍ (នៃឯករាជ្យ)

Délégué = ប្រតិភូ

Délégation = គណៈប្រតិភូ, ការបែងអំណាចឲ្យ

Minute = សំណៅ, នាទី

Original = សំណៅដើម, ច្បាប់ដើម

Copie = សេចក្ដីចំលង

Eventuel = ដែលជា យថាហេតុ, ស្រេចលើ យថាហេតុ

Eventualité = យថាហេតុ

(Le 20 — 5 -- 49)

garantie = ការសំអាង, ការធានា

Réserve = ឋបនីយ៍ (ឋ: – ប: – ណី)

Preuve = តឹកតាង, ព័ស្តុតាង, ឡាក់ឋាន

Métropole = } មាតុប្រទេស
Mère-Patrie = }

(Le 24  5 — 49)

Condition = ល័ក្ខខណ្ឌ

Spectacle = ទស្សនីយភាព

Disposition = បទបញ្ញត្តិ

Œuvre de bienfaisance = ការកុសល

Caractère = លក្ខណៈ, ចរិត, និស្ស័យ

Athlètisme = អត្តពលកម្ម

Culture physique = កាយសិក្សា

Nature = ធម្មជាតិ, ប្រភេទ

Bienfaisance = ការកុសល

Paysage = ទេសភាព

Admirable = បសំសនីយ៍, គួរស្ញើច, គួរកោត

Sport athlétique = កីឡាអត្តពលិក

Athlète = អ្នកអត្តពលកម្ម

(Le 31 — 5 — 49)

Préambule = លំនាំដើម, បុព្វកថា

Introduction = បុព្វយោគ, ពាក្យនាំ

Préface = អារម្ភកថា, ពាក្យប្រារព្ធ

Avant — propos កថាមុខ

Prologue = អារម្ភបទ

Epilogue = អវសានបទ

Livre de lecture = សៀវភៅហាត់អាន

(3 — 6 — 49

Dactylographie = អង្គុលីលេខ

Dactylographe = អ្នកអង្គុលីលេខ

Candidat libre = បេក្ខជនសេរី

| | |
|---|---|
| Communiqué = | សេចក្តីថ្លែងការណ៍ |
| — | សេចក្តីឲ្យការណ៍ |
| Proclamation = | ការប្រកាស |
| | (7 – 7 – 49) |
| Scepticisme = | លទ្ធិមដ្ឈ្យនិយម |
| Sceptique = | អ្នកមដ្ឈ្យនិយម |
| Optimisme = | លទ្ធិសុទិដ្ឋិនិយម |
| Optimiste = | អ្នកសុទិដ្ឋិនិយម |
| Pessimisme = | លទ្ធិទុទិដ្ឋិនិយម |
| Pessimiste = | អ្នកទុទិដ្ឋិនិយម |
| Sténographie = | ដរលេខ |
| Fermier = | មេភាស៊ី |
| Affermage = | ការបងភាស៊ី |
| Martyr = | ទុក្ករបុគ្គល |
| Auréole = | វង់រស្មី |
| Priorité = | អាទិភាព |
| Gloire = | កិត្តិគុណ |
| Saint = | សន្ត:, សន្តបុគ្គល |

Sainte = សន្ត (បរិសុទ្ធ)

Aspect = ទិដ្ឋភាព

Composition = សមាសភាព

(10 – 6 – 49)

Lier = ព័ទ្ធ ព័ន្ធ, ចង

Interview = សម្ភាសន៍ (ការសួរនាំឲ្យឆ្លើយ)

O malheur ! = ទុកម្មអើយ !

Misère ! = ពិបាកអ្វីម្ល៉េះ !

Douleur ! ទុក្ខអីខ្លាំងម្ល៉េះ !

Nous allons mourir ! ស្លាប់ឥឡូវហើយយើង

Quelle souffrance ! វេទនាអីម្ល៉េះ !

(21 – 6 – 49)

Ressortissant = អាណិកជន (ជនដែលនៅក្រោមអំណាចច្បាប់)

Révolution = បរិវត្តន៍

Titre d'Identité = អត្តសញ្ញាណប័ណ្ណ

Carte d'Identité = ប័ណ្ណសំគាល់ខ្លួន

(24 – 6 – 49)

Parole = ពាក្យសំដី, វចនាកាស

(មានត)

រឿងព្រេងភូមា

## លោក សាង-សារ៉ាត លេខានុការក្រសួងពិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

ព្រះនាងសន់ដាកុមារី លុះនិយាយរឿងនេះចប់ហើយ ក៏នៅស្ងៀមមួយស្របក់ ៗ ក្នុងពេលនោះ វត្ថុទាំងអស់ហាក់ដូចជាប្រមូលចូលក្នុងវិញ្ញាណរបស់ព្រះនាង ។ ទើបសួរទៅព្រាហ្មណ៍ទាំងបួន ម្នាក់ម្ដង ៗ ថា "បណ្ដាមនុស្សទាំងប៉ុន្មានដែលខ្ញុំបានពោលក្នុងរឿងនេះ តើអ្នកមានចិត្តសរសើរដល់មនុស្សរូបណា ?" ។

ព្រាហ្មណ៍ដែលចាស់ជាងគេឆ្លើយឡើងថា "ខ្ញុំសរសើរព្រះករុណាជាងគេ ព្រោះព្រះអង្គទ្រង់មានកិរិយាប្រកបតាមច្បាប់ទាំង ១០ ដែលស្ដេចគ្រប់អង្គតែងប្រព្រឹត្ត ខ្ញុំសរសើរ ដោយសារទ្រង់នៅវ័យក្មេង ក្លាហានមានឫទ្ធិអំណាច ហើយទ្រង់ចេះបង្ក្រាបតណ្ហាព្រះអង្គ មិនឲ្យស្នេហាចំពោះរូបនារីដែលបានសន្យានឹងព្រះអង្គ" ។

ព្រាហ្មណ៍ទី ២ និយាយថា "ខ្ញុំសរសើរទេវតាដែលរក្សាដើមពោធិ៍នោះ ព្រោះលោកបានឲ្យជើងពានមាសដល់នាង, មួយទៀត លោកជាទេវតាព្រៃ លោកចេះសង្កត់ចិត្តហានក្លាយោរយៅរបស់លោក ក្នុងឱកាសដ៏ប្រសើរនោះ ក៏លោកទប់ចិត្តបានមិនស្រឡាញ់នាង មិនដូច

មនុស្សយើងធម្មតា, ឯការណ៍ធ្វើចិត្តយ៉ាងនេះ ជាការមួយពិបាកណាស់" ។

ព្រាហ្មណ៍ទី ៣ និយាយថា "ខ្ញុំសរសើរប្ដីរបស់នាងជាងគេ ព្រោះបុរសនេះ មានចិត្តបរិបូណ៌ដោយកិរិយាប្រពៃណាស់ គឺចិត្តដូចជើងពានមាសមួយដែលគេដាក់ទឹកពេញប្រៀប ហើយនៅបាតជើងពានមាសនោះមានពេជ្រមួយគ្រាប់ផង, បុរសនេះនៅក្មេងហើយក្លាហាន ប៉ុន្តែគេបេះបង្អាក់ចិត្តគេមិនឲ្យកាន់ផ្លូវសំរេច រួចកាលដែលកិរិយាសុំចេញទៅកាលនោះគឺជាថ្ងៃដែលត្រូវផ្សំដំណេកផង បុរសនោះដាច់ចិត្តឲ្យប្រពន្ធនាងទៅដោយឥតរួញរាទ្បើយ, បុរសនោះឯងពិតជាមនុស្សមានជីវិតមួយយ៉ាងប្រសើរ ហើយមានចិត្តមួយយ៉ាងខ្ពង់ខ្ពស់បំផុត" ។

ក្រោយមក ដល់វេនព្រាហ្មណ៍កម្លោះនិយាយ ។ ព្រះនាងខត្តិយានីបានប្រឹងស្មារតីចាំស្ដាប់ ។ ព្រាហ្មណ៍កម្លោះក៏និយាយថា "បណ្ដាមនុស្សក្នុងរឿងនេះទាំងប៉ុន្មាន ខ្ញុំមានចិត្តសរសើរមេចោរជាងគេ ព្រោះធម្មតាមេចោរ តែងតែប្រថុយស្លាប់ជីវិតដើម្បីយកទ្រព្យគេ, ប៉ុន្តែក្នុងពេលនោះ មេចោរបែរជាឲ្យមាសពេជ្រ កងក ជើងពានមាសនឹងសំលៀកបំពាក់ទាំងប៉ុន្មានរបូតចេញពីកណ្ដាប់ដៃខ្លួនវិញ, នេះជាភស្តុតាងមួយយ៉ាងស័ក្តិសិទ្ធិ ដែលបង្ហាញឲ្យឃើញថា មេចោរនេះមានគំនិតនឹងចិត្តសទ្ធាប្រសើរណាស់ ខ្ញុំសរសើរតែមេចោរនេះទេ" ។

រួចនៅស្ងៀមទាំងអស់គ្នា ។ ស្រីស្នំរបស់ព្រះនាងខត្តិយានីដែលនៅជិតព្រះនាង និយាយខ្សឹបៗថា "ព្រះនាងឃើញប្លែកឬទេ? ព្រាហ្មណ៍

ទាំងបីនាក់សរសើរទៅគេ ព្រះករុណា ទឹងបុរសជាស្វាមី ដូចយើងបាន ធ្លៃគិតទុកដែរ; ឯព្រាហ្មណ៍កម្លោះបែរជាសរសើរមេចោរតែម្នាក់ឯង?" ។ ព្រះនាងឆ្លើយថា «ពាក្យឆ្លើយរបស់ព្រាហ្មណ៍កម្លោះនេះស្របនឹងគំនិតរបស់គាត់ពិតមែន, ខ្ញុំឃើញច្បាស់ថា គាត់នេះហើយដែលលួចមាសរបស់មិត្តសំឡាញ់គាត់ទាំងអស់គ្នា, ប៉ុន្តែមិនអីទេ · បន្តិចទៀតយើងគង់តែបានឃើញភស្តុតាងពិតប្រាកដមិនខាន, ចូរបងទៅក្នុងបន្ទប់របស់ខ្ញុំ យកសំលៀកបំពាក់របស់ខ្ញុំ ស្លៀកពាក់រូបតុបតែងខ្លួនយ៉ាងណាឲ្យបានដូចខ្ញុំ, ធ្វើយ៉ាងនេះរួចហើយ បងទៅរកព្រាហ្មណ៍កម្លោះក្នុងសួនច្បារ កាលណាព្រាហ្មណ៍កម្លោះនេះនៅតែឯង បងត្រូវនិយាយដូចតទៅនេះថា "បង! ពាក្យដែលព្រាហ្មណ៍ទាំង ៣ នាក់បាននិយាយជាពាក្យចចាមអារាមទេ ឯពាក្យរបស់បងវិញ ជាពាក្យអ្នកមានប្រាជ្ញាពិត ខ្ញុំសរសើររូបបងជាខ្លាំង សុំឲ្យបងស្តាប់ខ្ញុំ ដ្បិតបងនៅលីវ ខ្ញុំស្រឡាញ់បងណាស់ សុំឲ្យបងយល់ព្រមរៀបការនឹងខ្ញុំ" លុះកាលណាព្រាហ្មណ៍កម្លោះបង់ទទួលតាមបងហើយ បងនិយាយបន្ថែមទៅទៀតថា "បងយល់តាមប្អូនហើយ ប៉ុន្តែយើងត្រូវធ្វើយ៉ាងណា ដើម្បីចិញ្ចឹមជីវិតជាមួយគ្នា, ឥឡូវបងបាត់ទ្រព្យធនធានអស់ទៅហើយ ឯចំណែកខាងខ្ញុំជាប្អូនមានតែមាសពេជ្របន្តិចបន្តួចទេ ហេតុដូច្នេះ យើងត្រូវតែឃ្លាតគ្នាមួយគ្រាសិន ចាំទំរាំតែខ្ញុំបានស្រុះស្រួលនឹងឪពុករបស់ខ្ញុំ រួចយើងនឹងបានទៅជាអ្នកមានពុំខាន; ប៉ុន្តែពីនេះទៅ នោះយើងមុខជារកអាហារចិញ្ចឹមជីវិតដោយលំបាកពុំខាន;"

ដល់និយាយយ៉ាងនេះរួចហើយ ត្រូវបងមកប្រាប់ខ្ញុំវិញភ្លាម តើព្រាហ្មណ៍កម្លោះនិយាយយ៉ាងណាខ្លះ ៗ

ឯស្រីស្នំក៏ខំផ្ចិតផ្ចង់ធ្វើតាមពាក្យព្រះនាងខត្តិយានី ដោយឥតរំលងកន្លែងណាឡើយ ៗ នាងបានទៅរកព្រាហ្មណ៍កម្លោះហើយនិយាយគ្រប់ប្រការដោយប្រើសំឡេងយ៉ាងទន់ភ្លន់ តាមពាក្យបង្គាប់របស់ព្រះនាង ៗ ព្រាហ្មណ៍កម្លោះមានចិត្តត្រេកអរពន់ពេក ហើយនិយាយឡើងថា "ចូរអ្នកកុំព្រួយបារម្ភអ្វីឲ្យសោះ មាសបងគ្មានបាត់ទេ បងបានបញ្ឆោតថាបាត់ ដើម្បីឲ្យព្រាហ្មណ៍ទាំងបីចែកមាសឲ្យបងថែមទៀត ប៉ុន្តែបងមានទ្រព្យគ្រប់គ្រាន់ល្មមចិញ្ចឹមជីវិតយើងបានតាមត្រូវការ ទោះបីយើងទៅនៅស្រុកណាឆ្ងាយក៏ដោយ យើងក៏មិនស្លាប់ដែរ" ៗ

នាងធ្វើល្បិចបញ្ឆោតថា នាងទៅរៀបចំខ្លួន ដើម្បីនឹងរត់ទៅ តែដោយពិតនាងមករកព្រះនាងខត្តិយានី ហើយនិយាយអំពីការពិភាក្សាដែលនាងបានធ្វើជាមួយព្រាហ្មណ៍កម្លោះ ៗ

ព្រះនាងខត្តិយានីចូលទៅជិតឪពុករបស់ព្រះនាងភ្លាមដោយឥតបង្អង់យូរឡើយ ហើយដំរាបថា "លោកឪពុក! រឿងនេះខ្ញុំបានរៀបចំស្រេចអស់ហើយ, ឯមាសដែលបាត់នោះ គឺនៅក្នុងកញ្ចប់ដៃព្រាហ្មណ៍កម្លោះ" ៗ នាងនិយាយបន្ថែមថា "បើសិនណាខ្ញុំបានមាសគ្រប់ចំនួនដែលបាត់នោះ ក្នុងរវាងពីរម៉ោង ខ្ញុំនឹងយកមាស ១០០ ដំឡឹងដែល

បាត់នោះមកជូនពុំបាន" ។ បិតាក៏ធ្វើតាមបំណងកូនយ៉ាងស្រួល, ព្រះនាងយកមាសនោះ ទៅប្រគល់ឲ្យស្រីបំរើដែលមានចិត្តស្មោះត្រង់នឹងព្រះនាងជាពន់ពេកនោះ ហើយបានផ្ដែផ្ដាំថា "ចូរឯងយកមាសនេះទៅបង្ហាញព្រាហ្មណ៍កម្លោះនោះចុះ" ។

ឯស្រីបំរើ ក៏ទៅរកព្រាហ្មណ៍កម្លោះដែលនៅចាំនាងក្នុងសួនច្បារ ដល់ហើយនិយាយថា "បងមានមាសចំនួនប៉ុន្មាន? បំណែកខាងខ្ញុំជាប្អូនមានមាសបន្តិចបន្តួចទេ គឺមានតែ ១០០ ដំឡឹងប៉ុណ្ណោះឯង ប៉ុន្តែបើយកទៅបញ្ចូលជាមួយរបស់បងផង យើងមុខជារស់នៅបានដោយសុខសប្បាយជាមួយគ្នាមិនខាន" ។ ព្រាហ្មណ៍កម្លោះលុះបានគិតយូរបន្តិច ក៏ឲ្យថង់មាសរបស់ខ្លួនមកនាង ។ កន្លង ២ ឬ ៣ នាទីក្រោយមក ថង់មាសនោះក៏បានដល់ដៃព្រះនាងឧត្តិយានី ។ ព្រះនាងក៏មានចិត្តត្រេកអរជាខ្លាំងហើយនិយាយថា "អ្នកបង យើងបានការហើយ កុំឲ្យបង្អង់យូរឲ្យសោះ ចូរបងទៅហៅព្រាហ្មណ៍ទាំង ៣ នាក់មក ហើយឲ្យព្រាហ្មណ៍ទាំង ៣ នោះយកមាសរបស់ខ្លួនមកផង ក្នុងព្រះនាមនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង" ។ ឯព្រាហ្មណ៍ម្នាក់ៗ ក៏ប្រញិបប្រញាប់យកមាសមកប្រគល់ឲ្យនាងឧត្តិយានី ។

លោកកុងស៊ុយ៍បានអញ្ជើញទៅទូលព្រះករុណា ព្រោះលោករកឃើញមាសវិញហើយ ។ ប៉ុន្តែលោកទូលព្រះករុណាដោយពិតត្រង់ថា

មាសនេះមិនមែនខ្លួនលោកគេឃើញទេ ដែលគេឃើញនេះ គឺបុត្ររបស់លោកដែលបានដឹកនាំស្រាវជ្រាវរករឿងដ៏លំបាកនេះ ៗ ព្រះករុណាទ្រង់ហៅព្រះនាងខត្តិយានី នឹងព្រាហ្មណ៍ទាំងបួនមក ៗ ព្រះនាងខត្តិយានីក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស ក្នុងរឿងនេះមានល្បិចអាក្រក់ នឹងការលួចមួយយ៉ាងធំដែលព្រាហ្មណ៍ម្នាក់បានធ្វើ ព្រាហ្មណ៍ទាំងបួននាក់នេះ សុទ្ធតែជាអ្នកប្រកបដោយសទ្ធិបរិយានឹងវិជ្ជាសាស្ត្រ ប៉ុន្តែមានព្រាហ្មណ៍ម្នាក់ ពុំទាន់ដកខ្លួនចេញឲ្យផុតពីបំណងនៅឡើយ; នូវខួរក្បាលមនុស្សតែងតែចង់គ្នាពីមួយទៅមួយ មិនថាអ្នកប្រាជ្ញឬអ្នកខ្លៅទេ, ឯខួរក្បាលនេះ អាចទៅជាទំកម្ពុរនៃបំណង កំហឹង នឹងតណ្ហាបាន អាស្រ័យហេតុនេះហើយបានជាក្នុងសៀវភៅធម៌របស់ព្រះពុទ្ធមាននិយាយថា ដំបូងត្រចៀកឮ រួចត្រចៀកបណ្ដាលឲ្យភ្នែកចង់ឃើញ, ឯបំណងរបស់ចក្ខុ ប្រទាញដល់ចិត្ត រួចជីវិតយើងប្រែប្រួលពីល្អទៅអាក្រក់ ហើយជីវិតនេះចងជាប់នឹងតំរេកក្នុងភពលោកយើងនេះ; ក្រោយមកជីវិតនេះធេងធោងបាត់ស្អាតល្អ ឯមនុស្សដែលមានជីវិតបែបនេះ អាចធ្វើអំពើអាក្រក់បានគ្រប់យ៉ាងដោយគ្មានអ្វីចប់ នឹងគ្មានវិប្បដិសារៈ; មួយទៀតមនុស្សបែបនេះ មុខជាធ្លាក់ខ្លួនក្នុងនរកវេទនា ពីទុក្ខមួយទៅទុក្ខមួយជាអចិន្ត្រៃយ៍ពុំខានឡើយ" ៗ

លុះនិយាយចប់ហើយ នាងទុនខ្លួនក្នុងទីចំពោះព្រះភក្ត្រស្ដេច ហើយដាក់មាសទាំង ៤ ចង់ នៅក្រោមព្រះបាទព្រះអង្គ ៗ ស្ដេចទ្រង់

បង្គាប់ឲ្យព្រាហ្មណ៍ម្នាក់ ៗ យករបស់ខ្លួនវិញ ។ លុះដល់វេនព្រាហ្មណ៍កម្លោះ ព្រះរាជាមានព្រះបន្ទូលថា " ម្ដេចក៏អ្នកថារបស់អ្នកបាត់ ឥឡូវនេះឃើញវិញហើយ " ។ អ្នកដែលខុសខ្លួនក៏ដាក់មុខចុះដោយការសញ្ជប់សញ្ជឹងពន់ពេក ។ នាងវត្តិយានីបង្គំទូលថា " សូមទ្រង់ព្រះមេត្តាប្រោស, ព្រាហ្មណ៍ទាំង ៤ នាក់នឹងត្រឡប់ទៅកាន់ព្រះវិហារ ដើម្បីទៅធ្វើសមណធម៌ជាថ្មីវិញ ឯព្រាហ្មណ៍ដែលខុសខ្លួននេះ នឹងកែប្រែគំនិតហើយកាន់ផ្លូវសន្តិចរិយាវិញហើយ ហេតុដូច្នេះ សុំព្រះអង្គទ្រង់ព្រះរាជានុញ្ញាតទោសឲ្យផងចុះ" ។

ក្នុងពេលនេះ នាងទេពធីតាដែលរក្សាស្វេតច្ឆត្របានស្រែកឡើងថា " ជយោ " លាន់ឮរំពងឡើង ។

ព្រះករុណា មានព្រះហឫទ័យសរសើរប្រាជ្ញារបស់នាងជាពន់ពេក ហើយទ្រង់លើកនាងជាអគ្គមហេសី ក្នុងព្រះរាជអាណាចក្រ ដោយទ្រង់គិតឃើញថា គ្មានអ្នកណាមួយ ចេះការកាត់រឿងស្មុគស្មាញបែបនេះបានទេ ។

អស់លោកសុភា ! ត្រូវលោកមានសេចក្ដីវាងវៃនឹងប្រាជ្ញា ក្នុងការជំនុំជំរះដែលគេប្ដឹងលោកឲ្យដូចរឿងនេះ ។ ត្រូវលោកយកតម្រាប់ធ្វើតាមនាងវត្តិយានី ដូជាម្នា៉ សារ៉ី ដែលបានបង្ហាញយើងនេះ ។

(មានត)

# រឿងសាមគ្គី

## កណ្ឌទី ៦

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

កង់ស៊ុនចាន នឹង អ្នួនសៀវក៏ប្រុងប្រៀបរៀបសេនាទាហានទៅវិញទៅមកយ៉ាងមាំមួន តាំងបន្ទាយកយទ័ពជាប់ដែនគ្នាខាងត្រើយស្ទឹងម្ខាងម្នាក់ ត្រឹមតែតាំងទ័ពជាប់នៅទីនោះប្រហែលមួយខែបាយ ។

វេលានោះ មានមនុស្សម្នាក់នាំយកដំណឹងនោះទៅប្រាប់លីយូនៅក្រុងតៀងហាន់តាមដំណើរដែលអ្នួនសៀវ នឹង កង់ស៊ុនចានតតាំងច្បាំងគ្នានោះគ្រប់ប្រការ ។ លីយូក៏នាំសេចក្តីនោះទៅជំរាបតាំងតុះ ។ ពិគ្រោះនឹងលីយូថា ដែលអ្នួនសៀវនឹងកង់ស៊ុនចានមានថ្វីដៃ ធ្វើពិជ័យសង្គ្រាមនឹងគ្នាដូច្នេះ យើងនឹងគិតប្រការដូចម្ដេច ? ។ លីយូថា អ្នួនសៀវនឹងកង់ស៊ុនចាននោះ សុទ្ធតែមានថ្វីដៃខ្លាំងពូកែណាស់ បានតតាំងច្បាំងគ្នានៅតំបន់ស្ទឹងក្អួនហូ យូរខែហើយ បើខាងណាមានជ័យជំនះ ខាងនោះក៏នឹងកំរើកឡើង យូរទៅគង់នឹងនាំឲ្យរំខានដល់ខ្លួនលោក បើដូច្នេះសូមឲ្យលោកតែងសំបុត្រព្រះតម្រាស់ព្រះចៅហៀនតេ ទៅហាមឃាត់ទាំងសងខាងឲ្យជាមេត្រីនឹងគ្នាទៅវិញ យូរទៅអ្នួនសៀវនឹងកង់ស៊ុនចាននឹងនៅក្នុងបង្គាប់បញ្ជាលោក ។ តាំងតុះឃើញត្រូវ ក៏តែងជាព្រះតម្រាស់ព្រះ

បៅហៀនគេជា២ ច្បាប់តាមពាក្យលិយូថានោះ ហើយឲ្យគៀវគីនឹងម៉ាយិត នាំទៅឲ្យអួនសៀវនឹងកង់ស៊ុនចាន ។

ឯអួនសៀវកាលដឹងដំណឹងហើយ ក៏ចេញទៅទទួលព្រះត្រមាស់តាមទំនៀមទម្លាប់ រួចនាំត្រឡប់ចូលទៅក្នុងបន្ទាយ លុះមើលដឹងសេចក្តីហើយ ក៏ព្រមទទួលប្រតិបត្តិតាមព្រះរាជត្រមាស់គ្រប់ប្រការ ។ រួចគៀវគីនឹងម៉ាយិតនាំគ្នាកាន់ព្រះត្រមាស់ ១ ច្បាប់ទៀត ជូនទៅឲ្យកង់ស៊ុនចានក្នុងបន្ទាយ ។ កង់ស៊ុនចានកាលដឹងសេចក្តី ក៏ទទួលប្រតិបត្តិតាមព្រះរាជត្រមាស់នោះ ហើយចាត់បំរើទៅចរចាប្រាប់អួនសៀវៗ ទទួលព្រមល្មមតាមគ្នា, ព្រះរាជបំរើទាំង ២ នាំសេចក្តីត្រឡប់ចូលទៅក្រុងតៀងហាន់, ខាងអួនសៀវលើកពលត្រឡប់ទៅក្រុងគីជីវិញ ។

ចំណែកកង់ស៊ុនចាន បានរៀបចំសេនាទាហានហើយនាំឡៅពី គួនអ៊ូ គៀវហ៊ុយ ជូឡុង លើកទ័ពត្រឡប់ទៅខែត្រ, លុះដល់ស្រុកផេងងួនគួនឡៅពី គួនអ៊ូ គៀវហ៊ុយលាចូលទៅនៅនិយាយរាជការដូចដើម ។ ជូឡុងបាននិយាយនឹងឡៅពីថា កាលពីដើមមក ខ្ញុំឃើញអួនសៀវជាមនុស្សអាក្រក់បានជាត្រឡប់មកនៅនឹងកង់ស៊ុនចាន ឥឡូវនេះខ្ញុំបានឃើញថាកង់ស៊ុនចានជាមនុស្សគ្មានដំរេះប្រាជ្ញាសោះ ក៏មានសេចក្តីព្រួយលំបាកក្នុងចិត្តពន់ពេក ដល់ខ្ញុំបានបានឃើញលោកមានសតិបញ្ញាក្លៀវក្លាគិតថានឹងចង់ចូលសមាគមជាមួយផង ប៉ុន្តែទាស់នៅឆ្ងាយដាច់ស្រយាលពីគ្នា

ពេក ខ្ញុំបាទមិនដឹងជាទឹងគិតបែបណា ៗ ឡៅពីតបដោយយកចិត្ត ជូឡុងថា អ្នកនឹងយើងស្គាល់ចិត្តគ្នាក្នុងគ្រានេះ ក៏ត្រូវនៅកប់កាន់ជាស្និទ្ធ ស្នាលនឹងគ្នាតទៅ តែឥឡូវនេះត្រូវអ្នកទ្រាំនៅជាមួយនឹងកុងស៊ុនចាន សិនចុះ បើជីវិតយើងនៅមានទៅខាងមុខទៀត អ្នកក៏គង់បានជួបប្រសប់ ធ្វើការជាមួយមិនខានទេ អ្នកចូរចាំពាក្យនេះទុកកុំភ្លេច ៗ ឡៅពីទាញ ដៃជូឡុងចូលទៅជិតហើយ ក៏មានសេចក្ដីសៅសោក ៗ ជូឡុងក៏យំ អាល័យឡៅពី ហើយឡៅពីលាជូឡុងចូលទៅក្នុងស្រុកផេងង៉ួនគួន, កុងស៊ុនចាននាំជូឡុងលើកទាហានទៅស្រុកប៉ាក់ប៉េង ៗ

ឯអួនសុតចៅហ្វាយស្រុកខ្យាយ៉ុង លុះដឹងដំណឹងថា អួនសៀវ ជាបងបានស្រុកគីជីវជូ ឡោះ ក៏ធ្វើសំបុត្រ ១ ច្បាប់ឲ្យនាំទៅជំរាបសុំសេះ អួនសៀវមួយពាន់, តែអួនសៀវមិនព្រមឲ្យដូចប្រាថ្នា, អួនសុតខឹងណាស់ មានសេចក្ដីព្យាបាទអួនសៀវជាបង អួនសុតធ្វើសំបុត្រទៅសុំស្បៀងអា-ហារពីឡៅពៀវចៅហ្វាយស្រុកកេងជីវវិញ ខាងឡៅពៀវក៏មិនព្រមឲ្យ ស្បៀងអាហារទៅអួនសុត ៗ ក៏ខឹងចងព្យាបាទនឹងឡៅពៀវទៀត ៗ អួន សុតធ្វើសំបុត្រទៅដល់ស៊ុនកៀនចៅហ្វាយស្រុកកាំងតាំងថា ឡៅពៀវ លើកទាហានចេញស្ទាត់ច្បាំងដណ្ដើម យកត្រាសម្រាប់រាជ្យពីលោកនោះ ក៏ព្រោះអួនសៀវបងខ្ញុំឲ្យដំណឹង ឥឡូវនេះអួនសៀវនឹងឡៅពៀវរួមគំនិត គ្នានឹងលើកទ័ពមកវាយយកស្រុកកាំងតាំងដណ្ដើមយកត្រាឲ្យបាន រឿង

នេះបើលោកនឹងតាំងចិត្តសម្ងំស្ងៀមមិនគួរទេ ចូរប្រញាប់លើកទាហានទៅវាយស្រុកគេឯងវិញ ហើយទៅ ខ្ញុំនឹងជួយសង់សឹកលោក ហើយយើងលើកទ័ពប្រសព្វគ្នាទៅវាយស្រុកតិដរទៀតដែលអួនសៀវនៅនោះៗ ឯស៊ិនកៀនបានទទួលសំបុត្រដំណឹងសេចក្ដីហើយក៏ពេញចិត្តណាស់ ។ ទើបប្រឹក្សានឹងសេនាទាហានថា អ្នកឯណានឹងយល់ឃើញដូចម្ដេច? ចៀវផៅឆ្លើយតបថា ដែលអួនសុតឲ្យសំបុត្រមកនេះ យើងនឹងជឿស្ដាប់ពុំទាន់បាន ព្រោះអួនសុតនោះជាមនុស្សអាក្រក់រមែងញុះញង់ឲ្យអ្នកផងទៃទាស់ទែងគ្នា ម្យ៉ាងទៀតអួនសុតត្រូវជាប្អូនអួនសៀវផង ដែលថានឹងលើកទ័ពទៅច្បាំងនឹងបងរបស់នោះដូចមិនពិត ។ ស៊ិនកៀនឆ្លើយតបថា "ដែលចៀវផៅថានោះក៏ត្រូវហើយ តែថាឡៅពៀវនោះជាមនុស្សត្រង់នឹងយើង បើប្រសិនជាអួនសុតមិនមានសំបុត្រមកដល់យើងៗ មិនមែននៅស្ងៀមដែរ គង់តែលើកទ័ពទៅច្បាំង ការទាំងនេះមិនមែនដឹងឃើញដោយសារគេជួយប៉ុណ្ណោះទេ," ថាហើយក៏បង្គាប់អ៊ុយកាយឲ្យទៅកេណ្ឌប្រមូលទាហាននឹងរៀបយានជំនិះខាងផ្លូវដំណើរ ព្រមដោយទូកក្ដារប្រក់ថែវគ្រឿងសស្ត្រាវុធ មានទូកតូចធំផ្ទុកដាក់ស្បៀងអាហារបរិបូណ៌ ចាំដល់ពេលឫក្សល្អនឹងលើកព្យុហយាត្រា ។ ឯពួកកងត្រវែលល្បាត កាលបានដឹងដំណឹងច្បាស់ ក៏នាំសេចក្ដីនោះទៅជំរាបដល់ឡៅពៀវ ៗ ក៏ប្រជុំទីប្រឹក្សាថា ស៊ិនកៀននឹងលើកទ័ពទូកមកនោះ តើអ្នកទាំងអស់គ្នាយល់ឃើញ

ដូចម្ដេច ? ។ កេងលៀងឆ្លើយថា ដែលស៊ិនកៀនខឹងលើកទ័ពទឹកមកនោះ ឃើញថាទឹងគស៊ូទឹងយើងខាងទ័ពគោកមិនបានទេ ព្រោះបញ្ជូនស្បៀងលំបាក សូមឲ្យលោកកេណ្ឌទាហានរបស់ហងច ទៅហ្វាយត្រកគាំងហែ ដែលឡើងត្រែយើងគាំងផាទ័ពមុខ ខ្ញុំនលោកលើកជាទាហានទ័ពហ្វូង ។ ឡាពៀរឃើញត្រូវក៏ឲ្យទៅកេណ្ឌទាហានហងច លើកទៅគាំងនៅមាត់ព្រែកហ្វូនសៀ ហើយចាត់ចែងទាហានក្នុងស្រុកកេងជីវកេណ្ឌទុកតាមពាក្យកេងលៀងថា ។

ឯស៊ិនកៀនមានភរិយា ២ នាក់ជាបងប្អូនបង្កើតនឹងគ្នា បងឈ្មោះនាងង៉ីហ៊ូយិន ប្អូនឈ្មោះនាងង៉ីយ៉ហ៊ូយិន ។ នាងបងមានបុត្រប្រុស ៤ នាក់ ឈ្មោះស៊ិនសេក ១ ស៊ិនកួន ១ ស៊ិនសៀង ១ ស៊ិនខង ១ ។ នាងប្អូនមានបុត្រប្រុសឈ្មោះស៊ិនឡង១ បុត្រស្រីឈ្មោះស៊ិនយិន១ បុត្រប្រុសចិញ្ចឹមម្នាក់ទៀតឈ្មោះកងឡេ ។ ស៊ិនកៀនមានប្អូនប្រុសម្នាក់ឈ្មោះស៊ិនចេង, កាលថ្ងៃមានបុក្យល្អ ស៊ិនកៀនទឹងចុះទូកទៅនោះ ស៊ិនចេងជាប្អូនក៏នាំបុត្រស៊ិនកៀនទាំង ៧ នាក់ តាមចុះទៅឃាត់ស៊ិនកៀនថា គ្រានេះព្រះចៅហៀនតេប៉ុនសោយរាជសម្បត្តិ រាជការអាណាចក្រក៏ជាកម្ម-សិទ្ធិដាច់ខាតលើគាំងតុះ ។ ធ្វើការទុច្ចរិតអាក្រក់ អាណាខែត្រទាំងពួងក៏កើតចលាចលលែងចំណុះចុះចូលគ្នា អាណាប្រជានុរាស្ត្រក៏បានសេចក្ដីក្ដៅក្រហាយទូទាំងផែនដី ឥឡូវផែនស្រុកគាំងគាំងទើបនឹងរាបទាបជា

សុខសាន្តត្រាណហើយ ដែលអ្នកជាបងនឹងលើកទ័ពទៅច្បាំងនឹងឡេវពៀវចៅហ្វាយនៃត្រកេងជ៉ាវ សូមឲ្យត្រិះរិះរំពឹងមើលសិន ។ ស៊ុនកៀនតបថា កាលពីមុនមកខ្លួនយើងម្នាក់ឯង ម្តេចក៏ចេះតាំងខ្លួនឡើងបាន ឥឡូវយើងបានសេនាទាហានមកជាកម្លាំងដៃជើងច្រើនប៉ុណ្ណេះហើយ យើងនឹងលះបង់នៅស្ងៀមមិនទៅធ្វើការសងសឹកឡេវពៀវដែលជាគូសត្រូវឲ្យបានទេ ក៏ហាក់ដូចជាយើងមិនមែនកូនប្រុសជាជាតិទាហានមានថ្វីដៃ ។

ស៊ុនសេកឆ្លើយជំពបស៊ុនកៀនជាបិតាថា បើបិតាមិនព្រមឈប់, នឹងលើកទ័ពទៅឲ្យបាននោះខ្ញុំបាទក៏សូមទៅជាមួយផង ។ ស៊ុនកៀនមានសេចក្តីស្រឡាញ់ស៊ុនសេកជាទីបំផុត តែនឹងឃាត់មិនកើត ក៏ទទួលឲ្យទៅជាមួយ ហើយលើកទាហានចុះទូកចំបាំងឆ្លងឈូងសមុទ្រទៅដល់ពាមស្រុកហ៊ួនសៀប្រទល់នឹងស្រុកកាំងហែ ។

ចំណែកហាំងចោហ្វាយស្រុកកាំងហែដឹងតាមសំបុត្របង្គាប់អំពីឡេវពៀវឲ្យមក ក៏តាំងតែកេណ្ឌទាហានប្រមូលជាកងទ័ព ហើយលើកទៅបំរុងការនៅមាត់កំពង់ស្រុកហួនសៀ លុះឃើញស៊ុនកៀនលើកទាហានទឹកមកប្រពាក់ប្រពួនដល់មាត់កំពង់ ក៏តាំងតែឲ្យទាហានបាញ់ធ្នូចំរុះចុះទៅសំដៅទូកទាំងនោះ ។ ស៊ុនកៀនឃើញដូច្នោះក៏បំបាំងខ្លួន ថយទូកបញ្ឆោត បណ្តែតឲ្យបាញ់ដល់ ៣ ថ្ងៃ ៣ យប់ ទាហានកងទ័ពទូកក៏មិនមានសេចក្តីអន្តរាយ ។ ហាំងចក៏ឲ្យបាញ់បន្ថែមទាល់តែអស់ព្រួញ ។

ឯស៊ុនកៀនបានដឹងថា ព្រួញឈប់ស្ងាត់ហើយ ក៏ឲ្យទាហានដកយកព្រួញដែលជាប់នៅនឹងទូកទាំងអស់បានចំនួនព្រួញប្រហែលដប់ប្រាំម៉ឺន ៗ

ពេលនោះ មានខ្យល់បក់ត្រឡប់ខ្នប់ច្រាំង ស៊ុនកៀនឲ្យបែរទូកចំ·ចាំងចូលទៅចត ហើយឲ្យបាញ់ផ្ទួឡើង ៗ ទាហានហងចអស់ព្រួញហើយ ឃើញទឹងតទល់ពុំឈ្នះ ក៏លើកទ័ពថយចូលស្រុកហួនសៀ. ឆៀវផៅនឹងអ៊ុយកាយ ឃើញដូច្នោះ ក៏លើកទាហានបំបែកជា ២ កងដេញប្រកាប់ជាប់ចូលទៅដល់ទ្វារស្រុកហួនសៀ, ស៊ុនកៀននឹងហាន់តុងក៏លើកទាហានទ័ពជំនួយប្រពាក់ប្រពួនចូលទៅទៀត លុះឃើញហងចថយទ័ពចូលទ្វារស្រុក ក៏បរទាហានសម្រុកតាមទៅក្នុងស្រុកនោះបាន, ហងចទប់ទល់ពុំឈ្នះ ក៏ត្រឡប់រត់ទំលាយចេញទៅនៅស្រុកគេងសៀ ៗ ស៊ុនកៀនបានការក៏ឲ្យអ៊ុយកាយលើកពលត្រឡប់ទៅថែរក្សាទូកចម្បាំង ឯខ្លួនលើកទាហានតាមហងចទៅទៀត, ហងចឃើញស៊ុនកៀនទទ្រានលើកតាមទល់នឹងកំពែងស្រុកដូច្នោះ ក៏លើកទាហានចេញមកច្បាំងតទល់នៅក្រៅកំពែង ៗ (មានត)

> កំពុងខឹងគ្មានដឹងអ្វី ដល់សេចក្តីក្រោធស្ងប់
> ត្រឡប់ជាវិប្បដិសារី (ស្តាយក្រោយ) ។

យូរ - អ៊ុន

ភាគទី ២

សម័យឧដុង្គ

# អ្នកឧកញ៉ាវេទពិទូរ ឈឹម - ក្រសេម រៀបរៀង

(តទៅ)

ព្រះនាងនេះជាប់ត្រកូលព្រះរាជលោហិតតមកអំពីព្រះបាទហរិរ័ន្ធទី ១ នឹងព្រះបាទត្លៀសាណាវ័ន្ធទី ២. ទ្រង់មានព្រះរាជឱរស២អង្គព្រះនាមទទ-យាទិត្យវ័ន្ធ ១ ហរិវ័ន្ធ ១ ដែលបានទទួលរាជសម្បត្តិតទៅទាំងពីរអង្គៗ

ក្នុងរជ្ជកាលនេះ មានព្រាហ្មណ៍ប្រាជ្ញឈ្មោះ **សទាសិវៈ**, ជាកំស្តេងស្រីជ័យេន្ទ្របណ្ឌិត ជារាជបុរោហិតរបស់ព្រះអង្គ ៗ ប្រវត្តិសង្ខេបរបស់ព្រាហ្មណ៍នេះ ថា សទាសិវៈ នៅស្រុកកុតិក្នុងបូពាទិស មានសេចក្ដីចេះដឹងទាំងផ្លូវគតិលោក ទាំងផ្លូវគតិធម៌ ប្រាកដកេរ្តិ៍ឈ្មោះជាអ្នកប្រាជ្ញធំ ៗ ក្នុងសម័យមួយ សទាសិវៈ បានចេញទៅបួស តែមិនដឹងជាបួសបានប៉ុន្មានវស្សា. ព្រះបាទសូរ្យវ័ន្ធទ្រង់និមន្តឲ្យសឹកមក ហើយព្រះរាជទានរាជកុមារី ១ អង្គ ត្រូវជាកនិដ្ឋភគិនីរបស់ព្រះអគ្គមហេសីនៃព្រះអង្គឲ្យជាភរិយា រាំងទ្រង់តាំងជារាជបុរោហិតក្នុងរាជសំណាក់ មាន

---

១ មានព្រះអនុជ ២ អង្គ ព្រះនាម សទាសិវៈ ១ ជយេន្ទ្រវ័ន ១ ។

ងារជា **កំស្តេងស្រីជយេន្ទ្របណ្ឌិត** មានមុខការជាទីប្រឹក្សាការផែនដី ការព្រះសាសនា នឹងការធ្វើពិធីផ្សេងៗ (ថ្វាយ) តាំងទ្រង់គាំងជា **ខ្លោញកម៉ាន្ត** គឺជាមេជាងធំរបស់រាជការ ។ ព្រះមហាក្សត្រទ្រង់ប្រស្រ័យកិច្ចការផ្សេងៗ នឹងស្រីជយេន្ទ្របណ្ឌិតនេះជាយ៉ាងច្រើន ។

**ការផ្ដែកអាណាចក្រ**– ព្រះបាទស្សូរ្យវង្សទ្រង់បានក្រោបអរិរាជសត្រូវទាំងក្នុងប្រទេសទាំងក្រៅប្រទេស ចាប់តាំងពីព្រះអង្គទ្រង់នៅជាតំណែងមហាឧបរាជដូចបានពណ៌នាមកហើយ, ដល់មកពេលព្រះអង្គបានគ្រងពិភពកម្ពុជាហើយ ក៏នៅតែមានការណ៍បះបោរក្នុងប្រទេសតមកទៀត, ព្រះអង្គគោងព្យាយាមក្រោបរហូតដល់ឆ្នាំ ព. ស. ១៤៤៣ ទើបបានសាន្តត្រាណរៀបរយ ។

ព្រះរាជអាណាចក្រក្នុងរជ្ជសម័យនេះ ប្រាកដជាបានរីកធំទូលាយជាងរជ្ជកាលមុនៗនេះជាច្រើន គឺប៉ែកទិសនិរតី លាតសន្ធឹងទៅដល់កោះម៉ាលកា រាប់ថា ឆ្ងាយមិនមែនតិច ។ ខាងប៉ែកទិសពាយ័ព្យ បាននគរលំភូនរបស់មន បញ្ចូលមកក្នុងព្រះរាជអាណាចក្រកម្ពុជា ១ ភាគទៀត ។ ការគ្រប់គ្រងក្នុងរជ្ជកាលនេះ បានប្រព្រឹត្តទៅតាមប្រវេណីដើម គឺភាគមធ្យមរដ្ឋនៅក្នុងអំណាចព្រះអង្គគ្រប់គ្រងផ្ទាល់, ភាគបច្ចន្តរដ្ឋទាំងប៉ុន្មានគង់ឲ្យមានមហាឧបរាជគ្រប់គ្រង ទំនងដូចជាប្រទេសរាជកម៌ក ៖

រដ្ឋមាល័យ ទ្រង់តែងតាំងព្រះរាជវង្ស ១ អង្គឲ្យទៅគ្រប់គ្រង តែព្រះរាជវង្សនោះព្រះនាមដូចម្តេច មិនប្រាកដ ។

រដ្ឋាកាវតី ទ្រង់ឲ្យព្រះចក្រវត្តិគង់នៅជាមហាឧបរាជតមក ។ លុះដល់ឆ្នាំ ព. ស. ១៥៥៨ ព្រះចក្រវត្តិទិវង្គត ទ្រង់តែងតាំងព្រះរាជវង្សព្រះនាម ព្រះបន្ទ្រជោតិ ឲ្យគ្រប់គ្រងតមក ។ ព្រះបន្ទ្រជោតិមានព្រះអគ្គទេវី ព្រះនាម បដិមាសុតាង្គបន្ទ្រ មានព្រះឱរស ១ អង្គ ព្រះនាម ព្រះនារាយណ៍ ។

នគរលំភូនជាមណ្ឌលធំ ១ គឺមានផ្ទៃទីមណ្ឌលពាយ័ព្យរបស់ថៃក្នុងបច្ចុប្បន្ននេះជាខេត្តដែន មានព្រំប្រទល់ជាប់នឹងប្រទេសភូមា ហើយដែលទើបបានមកខ្មែរក្នុងពេលថ្មីៗនេះ ទ្រង់តែងតាំងព្រះនាង ចាមទេវី ជាព្រះធីតានៃព្រះបន្ទ្រជោតិនៅលវបុរៈ ឲ្យគ្រប់គ្រងតាមសេចក្តីសុំរបស់ប្រជារាស្ត្រក្នុងដែននគរលំភូន ។ ការគ្រប់គ្រងរបស់ព្រះនាងចាមទេវីប្រព្រឹត្តទៅយ៉ាងល្អៗ មិនដូចការគ្រប់គ្រងរបស់មហាឧបរាជដទៃ ។

ប្រវត្តិព្រះនាងចាមទេវីទៅគ្រប់គ្រងនគរលំភូន មានសេចក្តីពិស្តារទៅក្នុងចាមទេវីវង្ស(១) សូមស្រង់សេចក្តីដោយសង្ខេបមកថ្លែងក្នុងទីនេះដូចតទៅនេះ ។

---

១ ចាមទេវីវង្ស គឺជាពង្សាវតាររបស់ព្រះនាងចាមទេវី ដែលព្រះថេរ ១ អង្គបានតែងឡើងជាភាសាមគធៈ គេឃើញមានសេចក្តីស្ទាវរៈជាប់ផុតត្រង់ដែលថា រឿងនេះជាពង្សាវតារប្រទេសកម្ពុជា តែត្រឡប់ជាគ្មាននិយាយក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជសោះ ។

ព្រះនាងចាមទេវីមានព្រះរូបប្រកបដោយបញ្ចពិធកល្យាណី ។ កន្លងកាលមុនសោយរាជ្យនេះ ព្រះនាងមានព្រះរាជស្វាមីហើយ ព្រះរាជស្វាមីនោះជាព្រះរាជវង្សដែរ តែទ្រង់មានព្រះហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនាខ្លាំងណាស់ បានលាព្រះនាងទៅទ្រង់ព្រះផ្នួស ។ ឯព្រះនាងក៏ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាណាស់ដែរ បានបើកអនុញ្ញាតឲ្យព្រះស្វាមីទៅទ្រង់ព្រះផ្នួស ។ វេលាព្រះស្វាមីទៅទ្រង់ព្រះផ្នួស ព្រះនាងទ្រង់គភ៌បាន ៣ ខែហើយ។ ក្រោយដែលព្រះស្វាមីទ្រង់ព្រះផ្នួសហើយ ព្រះនាងក៏ត្រូវតែងតាំងជាមហាឧបរាជនៅក្រុងនគរលំភូន ។ កាលព្រះនាងយាងទៅ បាននិមន្តព្រះពុទ្ធរូបសំខាន់ដែលព្រះនាងធ្លាប់គោរពបូជា ព្រមទាំងនិមន្តព្រះថេរខ្លះដែលធ្លាតក្នុងព្រះត្រៃបិដកយកទៅផង ។ ព្រះនាងនៅក្រុងនគរលំភូនមិនយូរប៉ុន្មាន ក៏ប្រសូតព្រះឱរសភ្លោះ គេបានថ្វាយព្រះនាម មហន្តយស ១ អនន្តយស ១ ។ ព្រះនាងគ្រប់គ្រងរដ្ឋប្រកបដោយគន្លងធម៌ អ្នកនគរលំភូនមានសេចក្ដីគោរពស្វាមិភក្ដិចំពោះព្រះនាងជាយ៉ាងពេក ។ ទ្រង់បានរៀបចំសាងនគរលំភូនឲ្យត្រូវតាមបែបផែន ហើយផ្លាស់ឈ្មោះជាថ្មី ហៅថា នគរហរិបុញ្ជ័យ (គំនរមាសប្រាក់) តែតាមសំឡេងសាមញ្ញហៅថា ហរិភុញ្ជ័យ ។ ព្រះនាងបានសាងវត្តស្ថានក្នុងព្រះពុទ្ធសាសនាជាច្រើន មានព្រះពុទ្ធរូបធំៗ ព្រះអារាម នឹងព្រះធាតុចេតិយដើម ។ វត្តស្ថានអំបាលនេះ នៅ

មានជាព័ស្តុតាងដរាបដល់បច្ចុប្បន្ននេះ ។ ព្រះរាជវង្សរបស់ព្រះនាងមាន ព្រះរាជទុរាសព្រះរាជនេក្តាជាដើម បានគ្រប់គ្រងនគរហោរិបុញ្ញ័យតរៀង មក ជាច្រើនព្រះអង្គប្តច្រើនសតវត្ស ដូចមានប្រាកដក្នុងតាមទេវីវង្ស នោះស្រាប់ ។

ចំណែករដ្ឋដទៃៀង ឬហៅ ស្ទួគាលោក ដែលមានរាជធានីនៅ កំពែងពេជ្រ ឬហៅថា កោសម្ពី នោះគង់មានព្រះមហាក្សត្រគ្រប់គ្រង ដូចអំពីដើម តែព្រះមហាក្សត្រក្នុងវេលានោះព្រះនាមដូចម្តេច មិន ប្រាកដក្នុងប្រវត្តិសាស្ត្រនេះ ។

ឯរដ្ឋគោត្របុរៈ ដែលមានរាជធានីតាំងនៅកិម៉ាយប្តូនគរភ្នំនោះ បានបញ្ចូលមកក្នុងមជ្ឈមរដ្ឋពីយូរណាស់មកហើយ វេលានេះគង់គ្មាន ព្រះមហាក្សត្រគ្រប់គ្រង តែគង់មានអ្នករាជការជាន់ខ្ពស់ដែលហៅតាម ភាសាបុរាណ សឹងប្រាកដនៅសិលាចារិកថា នាយក ៥ បតី (សឹង ត្រូវនឹងពាក្យក្នុងបច្ចុប្បន្នថា ចៅហ្វាយខែត្រ) ទៅនៅកាន់កាប់រាជការ ។

ចំណែកបច្ចន្តរដ្ឋបែកខាងកើត គង់មានមហាក្សត្រគ្រប់គ្រងតាម ប្រវេណីដើម តែព្រះមហាក្សត្រក្នុងសម័យនោះព្រះនាមដូចម្តេច មិន ប្រាកដ ។

(មានត)

សាវតារវត្តថាង យើ

នៅឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ

## លោកមេឃុំ ឌួង – អ៊ូច

ជាអាចារ្យវត្តនេះ រៀបរៀង

(ភ្ជាប់លេខ ១)

---

# វត្តបាធយ

ថ្ងៃពុធ ១ កើត ខែចេត្រ ឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ ត្រូវនឹងថ្ងៃ ៣១ មិនា ១៩៤៩ ។

ខ្ញុំបាទឈ្មោះ ឌួង-អ៊ូច អាយុ ៥៦ ឆ្នាំជាតិខ្មែរ ទីលំនៅភូមិជ្រៃ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ធ្វើអាចារ្យសំរាប់វត្តបានយ ឃុំ ស្រុក ខេត្តដដែល ។ ខ្ញុំសូមតែងពង្សាវតារ វត្តបានយ ជាវត្តដែលខ្ញុំបាននៅសិក្សារៀនអក្សរ តាំងពីកុមាររហូតដល់បព្វជ្ជា ជាសាមណេរ ជាភិក្ខុ តាមរឿងហេតុដែលខ្ញុំបានឃើញផ្ទាល់ខ្លួនខ្លះ ឮចាស់ៗនិយាយតៗមកខ្លះ ដូចមានអធិប្បាយខាងក្រោម ៖

កាលខ្ញុំអាយុ ១២ ឆ្នាំ មាតាបិតារបស់ខ្ញុំបានយកទៅទុកឲ្យនៅរៀនអក្សរនៅទីវត្តបានយនេះ; ក្នុងសម័យលោកគ្រូចៅអធិការនាម វង្ស-គង់ ធ្វើជាចៅអធិការ (ទី ៤) នោះមានអាចារ្យវត្តម្នាក់ឈ្មោះ ព្រាប-ម៉ុ អាយុ ៨០ ឆ្នាំប្លាយ ផ្ទះនៅជិតវត្ត គាត់ឧស្សាហ៍មកវត្តញយៗ បាននិយាយ

ប្រាប់ខ្ញុំថា វត្តនេះអាទិតាំងកៈហេតុសាងដំបូងឡើងគឺលោកតា វឿន ១ បួស ជាសង្ឃនិមន្តមកអំពីស្រុកសៀម លោកជាអ្នកចេះស្ងបារតហោះ លោកមកនៅទួលព្រៃតូច សង់រោង ១ ទៅស្ងបារត ហើយបានសង់រោងអ្នកតា ២ ឈ្មោះតាសុខ ១ តាស៊ីវ ១ ។ លោកគ្រូនោះថែរក្សាទុកជាគោលចារឹក ដើម្បីនឹងរៀបពិធីការស្ងបារត នឹង តាំងពិធីមន្តអាគមឲ្យបានពូកែធុតធាប់ បានជាមានជាប់ឈ្មោះអ្នកតាសុខ ១ អ្នកតាស៊ីវ ១ រហូតដល់មកសព្វថ្ងៃនេះ ។ លុះនៅយូរៗទៅ អ្នកស្រុកភូមិបានយដែលមានផ្ទះតូចៗ ចំនួន ៥-៦ ប៉ុណ្ណោះ បានឃើញលោកគ្រូនោះចេះស្ងបារតហោះ ព្រមទាំង ចេះមន្តអាគមស្រោចទឹកធ្វើខ្សែ មានថ្នាំកែរោគផ្សេងៗ ពូកែធុតធាប់ដូចបំណង ក៏នាំគ្នាទៅមករាប់អានយកកូនចៅទៅទុកឲ្យនៅរៀនសូត្រ ហើយជួយធ្វើកុដិសាលា រោងឧបោសថ ជាប់រហូតដល់មកសព្វថ្ងៃនេះ គេហៅថា វត្តបានយ ។ ។ តែទីវត្តនេះទំនងជាភូមិលាវអំពីដើម ដ្បិតនៅជិតខាងវត្តនេះ មានឈ្មោះភូមិគោកលាវ, ណងខែ, ណងតាសំ, ណងហ្វង, ណងសាង, ណងចក, ណងបិន, ប៉ាស្រែ, ប៉ាសិង, ប៉ាណាយ ក្លាយយូរទៅហៅ បានយ បើតាមពាក្យលាវ ប៉ាណាយ ប្រែថា "ព្រៃតូច" ត្រូវតាមទំនងវត្តនេះពីខាងដើម មានទួលព្រៃតូច ១ សមរម្យដូចពាក្យអាចារ្យ ព្រាប-មុី ប្រាប់ខ្ញុំមែន ។ វត្តនេះកសាងចំនួន ១៥០ ឆ្នាំឆ្ងាយមកហើយ កាលរាជ្យស្ដេចព្រះបាទអង្គ ឌួង ប្រហែលជា

គ្រិស្តសករាជ ១៨៥០ ។ តាំងពីកសាងវត្តនេះដរាបដល់មកសព្វថ្ងៃនេះ ៥ រាជ្យស្តេចមកហើយ, ដែលខ្ញុំបានដឹងថាក្នុងរាជ្យព្រះបាទអង្គឌួងនោះ ព្រោះខ្ញុំគិតពីត្រឹមមន្ត្រីចាស់ម្នាក់ឈ្មោះ មៅ ងារការជា ពិភ័ក្តិស្រាម ធ្វើជានាយកចាំទ្វារនៅទីសន្ទម្មទឹងព្រះកែវមរកតក្រុងភ្នំពេញ គាត់បានធ្វើរាជការក្នុងរាជ្យព្រះបាទនរោត្តម កាលដែលលើកទីក្រុងពីឧត្តុង្គមកភ្នំពេញវិញ, គិតពីត្រឹមនោះមកចៅអធិការវត្តបានយនេះចំនួន ៩ រូបមកហើយ ដូចមានរាយនាមខាងក្រោម :

១ — ចៅអធិការ ទៀង
២ — " សេក
៣ — " អ៊ុក
៤ — " រ័ត្ន — គង់
៥ — " ដែក — គឹម
៦ — " ស្រី — ស៊ុម
៧ — " សុខ — គល់
៨ — " ឆ៉ាយ — ម៉ាង
៩ — " ស — អ៊ិន

ពង្សាវតារវត្តបានយ សង្ខេបតែប៉ុណ្ណេះ ។

## អធិប្បាយអំពីនាទីដីដែលសាងវត្ត

បើតាមក្បួនត្រៃភូមិ ត្រូវរើសរកដីខ្ពស់ខាងត្បូងទឹងខ្ពស់ខាងលិច

ទើបហៅថា ភូមិមានសិរី ៗ បើភូមិខ្ពស់ជុំវិញទាបកណ្ដាល ហៅភូមិសំបុកមាន់ នៅពុំស្រួលសុខប៉ុន្មានយូរ ៗ បើភូមិខ្ពស់កណ្ដាលទាបជុំវិញ ហៅភូមិមេលិមទង់ជ័យ នៅសុខសប្បាយ តែពុំសូវចូលទ្រព្យសម្បត្តិ ៗ

បើទីដែកសាងវត្តជាថ្មី តាមទំនៀមទំលាប់ដំបូងឲ្យរកដីបាន ១ បុស គឺដី ៨ យកមករៀបបញ្ជាន់ភូមិគ្រប់ទិស ហើយទើបបរដីមកប្រជុំគ្នានៅផ្ចិតភូមិ, ហើយមានរៀបណ្ដាប់ទៀន ៩ ធូប ៩ លាជផ្កាស្លាបារី ៩ ១ ដូចគ្នា, រៀបជា ៩ សំរាប់គ្រប់ទិស ឯបាយសី ៩ ថ្នាក់ ១ ដើមដាក់ត្រង់ផ្ចិតភូមិ, ហើយអាចារ្យសូត្របូជា មានតៃចែង ៨ ជូនទៅគ្រប់ទិស ហើយអាចារ្យសូត្រម្ចាប់ស្តុតិ សរព្រះនាគយណ៍មហាសម្បុរ ទើបអាចារ្យបោះគោលធំ ១ កណ្ដាលផ្ចិតភូមិ, មើលតាមនាមវត្ត បើវត្តមាននាមដូចម្ដេច ដូចជាវត្តបានយនេះជាដើម ត្រូវយកអក្សរខាងចុង ព្រោះមនុស្សប្រុសយកដើមអក្សរ, មនុស្សស្រី ស្រុក ភូមិ នគរ យកចុងអក្សរវិញ, ឧបមាដូចមនុស្សប្រុសឈ្មោះ នយ ត្រូវយកអក្សរ ន ខាងដើម; ចុះដូចជាស្រី ឬវត្ត ភូមិត្រូវយកអក្សរខាងចុងគឺអក្សរ យ ហើយមើលថាវត្តនេះត្រូវនាមអក្សរ យ, អក្សរ យ ត្រូវនាមអ្វី ជានាមដំរី ១, មូលនៅទិសណាថានៅទិសអគ្នេយ៍, ឲ្យរាប់អំពីទិសអគ្នេយ៍ជាដើមថា មូល, ឧស្សាហ៍, មន្ត្រី, កាឡកណ្ណី, បរិវារ, អាយុ, តេជះ, សិរី ៗ ត្រូវដាក់ផ្ទៃត្រង់ បរិវារ ឬតេជះសិរី បានទាំងអស់ វៀរតែកាឡកណ្ណី, ឯកាឡកណ្ណីសំរាប់សង់

បង្គន់, មូល សង់សាលាជំនុំ, គេជះ សង់ហោត្រៃ, មន្ទ្រី សង់កុដិចៅអធិការ, សិរី សង់ព្រះវិហារ ។

ឯព្រះវិហារបានដាក់បែរមុខទៅឯកើតនោះ ព្រោះធ្វើតាមបវេណីព្រះពុទ្ធដែលបានត្រាស់ដំបូង គេឃើញតែឆ្ពោះព្រះភក្ត្រទៅទិសឯកើត, ហើយទិសឯកើតនេះ ជាលំនៅដើមរបស់ព្រះអាទិត្យ តែងគោចរពីទិសឯកើតទៅឯលិចតាំងពីដើមរៀងមកជាដរាប ។ ព្រះវិហារបានជាមានរូបនាគជាសត្វតិរច្ឆាននៅបាំងលើនោះ គឺធ្វើតាមរឿងកាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទើបបានត្រាស់ថ្មីៗ ទៅគង់នៅមុជលិន្ទស្រះ ភ្លៀងបង្អុរចុះ ៧ យប់ ៧ ថ្ងៃលិចផែនដី ទើបស្ដេចនាគទៅក្ដាយរង្វេលធ្វើជាបល្ល័ង្កលើកពពារឡើងបាំងភ្លៀងកុំឲ្យទទឹកព្រះអង្គ បានជាជាប់ទំនៀមទំលាប់ពីនោះមក ។ សេចក្ដីនេះតាមមតិរបស់ខ្ញុំយល់ឃើញតាមគម្ពីរបឋមសម្ពោធិ ។

ឯពិធីដែលកសាងព្រះវិហារដំបូង មេជាងបង្គាប់ឲ្យរៀបរណ្ដាប់ព្រះពិស្ណុការមានក្បាលជ្រូក ១ គូ, បង្អែម៨, ចំអាប៨, ស្លាធម៌៨, ផ្តិលទឹក៨, សំពត់ផ្នត់ ៨, ប្រាក់ ៨ រៀល, ស្រូវ ១ កន្តាំង, ជម ៤, អង្ករ ១ ថាង, ទៀន ១ ដើម, សំពត់ស ៤ ហត្ថ, ទៀន ៤, ធូប ៤, លាជផ្កាស្លាបារី ៤ៗ ដូចគ្នា. ប្រមូលចាស់ព្រឹទ្ធាចារ្យមកជុំ ហើយអុជទៀនធូបសំបួងសួងថា "ឱតេជតេជៈ ថ្ងៃនេះថ្ងៃជាពេលាល្អ ព្រះភូមិព្រះករព្រះធរណីម្ចាស់ទឹកម្ចាស់ដីព្រះពិស្ណុការ ព្រះបារមីស្សូរ ដ្បិតយើងខ្ញុំទាំងអស់គ្នាកសាងព្រះវិហារថ្មី សូមព្រះពិស្ណុការព្រះបារមីស្សូរជួយកាន់ខ្នងរងមុខ ឲ្យជាង

ធ្វើការនេះកុំឲ្យបែកដៃបែកជើង ឲ្យបានសុខចំរើនគ្រប់ប្រការ ” លុះបួន ស្ទឹងគ្រប់ ៣ ដងហើយលើកត្បូងកន្ទេរ ក៏យកឃ្លោះបាយផុតផាវផុតក្រដាស សត្វគ្រប់ហើយ ទើបគេបារ្យាខាសបួលទៅអង្គុយកណ្ដាល សូត្រ អញ្ជើញព្រះពិស្ណុការថា ភុម្មិ ជម្ម សង្ឃ ឃរ៉ា ឥ យោ សោ ពិស្ណុការេ ធោ ឃហិ ឫជូបការណំ សត្វត្យញ្ជូនំ ឫភាមិ ។ ៣ ដង ។ ហើយសូត្រអញ្ជើញព្រះពិស្ណុការ សូត្រថ្វាយ បាយព្រះពិស្ណុការ ។ ឯធម៌ទាំងអស់នេះ ខ្ញុំមិនបានយកមកអធិប្បាយក្នុង ទីនេះទេ ព្រោះសេចក្ដីនេះវែងពេកនាំឲ្យខាតពេលវេលា ។ ឯប្រជាប់ពិ-ការ ទីធម៌សូត្រអញ្ជើញព្រះពិស្ណុការ ដូចបានរៀបរាប់មកទាំងអស់ នេះ ខ្ញុំបានដឹងអំពីសំណាក់លោកគ្រូព្រះសិរីវង្ស វត្តពោធិ៍ពាម នាម ឡុង មេគណស្រុកកោះធំ ខេត្តកណ្ដាល លោកបានកត់ជារបៀបឲ្យ ខ្ញុំធ្វើអាចារ្យទុកសំរាប់តទៅ ។

## ពិធីបញ្ចុះសីមា

អំពីនេះ នឹងអធិប្បាយអំពីរឿងបុណ្យបញ្ចុះសីមាសំរាប់ព្រះសង្ឃធ្វើ សង្ឃកម្មផ្សេង ៗ តាមដែលខ្ញុំបានឃើញផ្ទាល់ខ្លួន ។ ទំនៀមទម្លាប់ដែល ធ្លាប់ឃើញអាចារ្យជាន់ចាស់ៗ ខ្មែរ ១ មកគឺដំបូងគេទៅរកទិញថ្ម ឬស សីមាទីងស៊ីកសីមាដែលជាងចេញធ្វើស្រេច ចំនួន ៩ ដុំ មានទំហំមិនធំមិន តូច ទម្ងន់ប្រហែល ២ ហាប ហើយដង្ហែនាំទៅទុកក្នុងទីព្រះវិហារ ទើប ប្រជុំគ្នាជា ៩ ក្រុមដើម្បីចាប់ឆ្នោតរើសរកអាចារ្យ ៩ នាក់ ជាអ្នកអង់អាច

ឈ្មោសកាន់ទៅ ធ្វើឆ្នោត ៩ កូនសេចក្តីឆ្នោតដាក់ថា ទិសបូព៌ា, អគ្នេយ៍, ទក្សិណ, និរតី, បស្ចិម, ពាយ័ព្យ, ឧត្តរ, ឦសាន, ឥន្ទកីល ។ បើអាចារ្យណាចាប់ត្រូវទិសណា អាចារ្យនោះត្រូវរៀបតាំងពិធីទិសនោះ; បើអាចារ្យណាចាប់ត្រូវឥន្ទកីលត្រូវលើកអាចារ្យនោះជាធំ ជាចាងហ្វាងត្រួតត្រាការខុសត្រូវក្នុងបុណ្យទាំងអស់ ។ លុះចាប់ឆ្នោតរួចស្រេចហើយអាចារ្យទាំង ៩ នាក់ជុំនុំគ្នាពីទេយ្យទានអ្វីខ្លះសម្រាប់ប្រគេនដល់លោកសង្ឃមួយអង្គ ៗ លុះជុំនុំមូលមាត់គ្នាហើយអាចារ្យធំសម្រេចសេចក្តីថា បើលោកអាចារ្យណាគិតប្រដាប់បានប៉ុន្មាន ត្រូវនិមន្តលោកប៉ុណ្ណោះអង្គតាមប្រដាប់ចុះ, ហើយជីករណ្តៅគ្រប់ទិសតាមទិសដែលខ្លួនត្រូវឆ្នោត, រួចយកអំបោះចងស្លាក់ឫសសីមាសឹកឈើឲ្យបន្តោកនៅមាត់រណ្តៅហើយរៀបគ្រឿងសក្ការៈបូជាតាំងនៅបៀតមាត់រណ្តៅតាមទិសរៀងខ្លួន ៗ លុះដល់ពេលល្ងាច ប្រជុំនមស្សការនិមន្តលោកចំរើនព្រះបរិត្តគ្រប់ទិស ហើយអាចារ្យធំមើលឫក្សពារវេលា តាមពេលសុរិយៈ ដូចបានរៀបរាប់ជាសង្ខេបខាងក្រោមដូច្នេះ: សូរិយៈ, សុក្រៈ, ពុធៈ, ចន្ទ្រា, សៅរេ, គុរុ, កុម្ភៈ ៗ តាំងលេខ ៣ ជួររួចដាក់ពេលថា: ព្រឹកពន្លឺតូច, ពន្លឺធំ, ទៀបត្រង់, រសៀលតូច, រសៀលធំ, គន់ក្នុ, គោចូលក្រោល ។ រួចហើយបូកបានប៉ុន្មានត្រូវត្រាទុក ហើយយក ៣ គុន ៧ ហារ, បានចំត្រូវពេលណា ទើបអាចារ្យធំប្រាប់ថាថ្ងៃនេះ ពេលម៉ោងប៉ុណ្ណោះត្រូវចាំស្តាប់

ស្រូវគេចាំងអន្ទង់ ដល់អន្ទង់បង្ហើយឲ្យគាត់ប្ញសសីមាទំលាក់ឲ្យស្រែះព្រមគ្នា កុំឲ្យបាញ់មួយ ៗ, ហើយអាចារ្យធំប្រាប់ថាបើលោកគ្រូធំជាចៅអធិការ ត្រូវឆ្នាំកំណើត ឬត្រូវឡាក់ហ៊ួយតួងលើថ្ងៃទន្សាកំណើត ដល់ពេលគាត់ ប្ញសសីមា និមន្តចយចេញឲ្យផុតស្រូវគេងស្ងារដើម្បីកុំឲ្យបាញ់មេវត្ត តាមទំនៀមទំលាប់រៀង ១ មក ។ រឿងនេះខ្ញុំបានឃើញច្បាស់នឹងភ្នែក កាលបញ្ចុះសីមាវត្តព្រៃផ្កាំ ឃុំព្រៃផ្កាំ ស្រុកព្រៃកប្បាស ខេត្តតាកែវ លោកគ្រូចៅអធិការវត្តនោះ នាម ជា; ដល់ពេលទឹងគាត់ប្ញសសីមាស្រាប់ តែលោកគ្រូនោះគេចខ្លួនគេបបាត់ដោយខ្លាចបាញ់ លុះដល់ព្រឹកឡើង ល្មមពេលឆាន់ព្រឹកក៏មិនឃើញវិលចូលមកវត្តវិញ លុះបាត់ដល់ថ្ងៃពេក ទើបកូនសិស្សយកចង្ហាន់ទៅប្រគេន ដើរតាមរកទំរាំឃើញក្នុងព្រៃស្ងៃកែ ហួសពេលឆាន់ លុះដល់ចូងបុណ្យរួចទើបហ៊ានទិមន្តចូលមកវត្តវិញ ។

ខ្លាចយ៉ាងនេះដែលពេក, កាលបុណ្យសីមានោះ ខ្ញុំបានធ្វើជាអាចារ្យ សមន្តរិកធំជាងគេ តែនៅកាន់តាមទំនៀមទំលាប់ ។ រឿងនេះមាន លោកគ្រូព្រះបទុមសីលាចារ្យមេគណស្រុកព្រៃកប្បាស នាម សួស ១ លោកគ្រូសិរីវង្សវត្តពោធិកបា នាម ឡុង ១, លោកគ្រូបាឡាត់ លាង វត្តសំប៉ានស្រុកកោះធំ ១ ទាំង ៣ អង្គនេះបាននិមន្តទៅបុណ្យ ធ្វើជា អធិបតី បានជ្រាបច្បាស់ប្រាកដដង ។

ចប់ពិធីបញ្ចុះសីមាសង្ខេប តែប៉ុណ្ណេះ (មាន៩)

បការ្ដទិ ៣

# រឿងព្រែងប្រទេសរ៉ូម៉ានី

លោក ផេង-ដើរ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ក្រុងភ្នំពេញ

ប្រែពីភាសាបារាំង

---

កាលដ៏កន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គមាននាមមិនប្រាកដ ទ្រង់ទសពិធរាជធម៌ ទ្រង់មានព្រះរាជបុត្រាបីព្រះអង្គ ។ ដទៃអំពីកុសលកម្មដែលទ្រង់តែងប្រទានចំពោះអាណាប្រជានុរាស្ត្រក្នុងព្រះនគរ ព្រះរាជាទ្រង់កសាងព្រះវិហារមួយ ដែលល្បីឈ្មោះរន្ទឺសុះសាយដល់ទីឆ្ងាយ ។ ព្រះរាជាទ្រង់ធ្វើលំអព្រះវិហារនោះដោយមាសដោយត្បូងពេជ្រ ដោយវត្ថុអ្វីដែលជាក្នុងព្រះបរិនិយមថាប្រសើរថ្លៃថ្លាបំផុត ។ សសរនៃព្រះវិហារទាំងខាងក្នុងទាំងខាងក្រៅ សុទ្ធសឹងជាវិការៈនៃថ្មកែវស្រោបមាស ។ គ្រឿងចម្លាក់យ៉ាងប្រសើរ ប្រដាប់ទ្រចង្កៀងដ៏រលើបចង្កៀងជាច្រើនដែលសម្រាប់អុជជាអចិន្ត្រៃយ៍ជាវិការៈនៃប្រាក់សុទ្ធ, គម្ពីរធម៌ដ៏ប្រពៃទុកដាក់យ៉ាងរៀបរយ, វត្ថុទាំងនេះទុកជាសម្បត្តិនៃព្រះវិហារ ។ ព្រះរាជាតែងមានព្រះហឫទ័យរីករាយយ៉ាងក្រៃលែង ព្រោះទ្រង់ទតឃើញព្រះវិហារល្អអស្ចារ្យនេះ, ប៉ុន្តែទ្រង់ព្រួយព្រះហឫទ័យមួយយ៉ាង ដោយការមិនអាចនឹងបង្ហើយនូវព្រះវិហារនោះ ព្រោះកំពូលស្រួចខាងលើកាលណាធ្វើរួចហើយចេះតែបាក់ធ្លាក់ចុះមកវិញជានិច្ច ។

ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះតម្រិះថា "អញប្រហែលមិនអាចនឹងបង្ហើយព្រះវិហារនេះទេដឹង? ទ្រព្យសម្បត្តិរបស់អញទាំងអស់ចំណាយទៅក្នុងព្រះវិហារ, តែព្រះវិហារនៅតែធ្វើមិនហើយ" ។

រួចព្រះអង្គបង្គាប់ឲ្យគេប៉ាវគងឃោសនាក្នុងព្រះនគរថា "បើជាងណាបេះ អាចបង្ហើយកំពូលព្រះវិហារនោះបាន ព្រះអង្គនឹងប្រទានរង្វាន់យ៉ាងស្ដុកស្ដម្ភ ហើយនឹងបញ្ចូលជាងនោះក្នុងត្រកូលនៃព្រះវង្សផង" ។ ក្នុងថ្ងៃជាមួយ ទ្រង់បង្គាប់ឲ្យប្រជារាស្ត្រសូត្រធម៌គ្រប់វត្ត ហើយឲ្យធ្វើបុណ្យផង ដើម្បីបន់ព្រះជាម្ចាស់ឲ្យជួយបញ្ជូនជាងយ៉ាងពូកែមក តាមសេចក្ដីព្រួយនឹងសេចក្ដីអង្វររបស់ទ្រង់ ។

លុះកន្លងមក ក្នុងយប់ទី ៣ ព្រះរាជាទ្រង់សុបិនថា: បើប្រសិនជាអ្នកណាមួយអាចទៅយកបក្សីទិព្វឯត្រើយសមុទ្រម្នាងបាន ហើយយកសត្វនុះទៅឲ្យនៅត្រង់កំពូលព្រះវិហារៗនឹងឈប់រលំ ។ លុះទ្រង់តើនពីផ្ទំ ព្រះរាជាបានថ្លែងសុបិននិមិត្តនោះប្រាប់ព្រះរាជបុត្រទាំងបីព្រះអង្គ ដើម្បីពិសោធមើល តើព្រះរាជបុត្រអង្គណានឹងជួយយកអាសាព្រះអង្គ ហើយនឹងចេញទៅស្វែងរកបក្សីទិព្វមុនគេបង្អស់? ។

ព្រះមហាក្សត្រ មានព្រះរាជឱង្ការថា: "ម្នាលបាទាំងឡាយ, បិតាយល់ច្បាស់ថាអ្នកទាំងបីមានបំណងនឹងបំពេញនូវករណីយកិច្ចចំពោះព្រះជាម្ចាស់ ប៉ុន្តែអ្នកទាំងបីមិនត្រូវចេញទៅស្វែងរកតែម្នាក់ស្របគ្នាឡើយ;

គឺត្រូវកូនច្បងចេញទៅរកមុន បើកិច្ចនោះមិនសម្រេច ជាភារៈកូនទី ២ ចេញទៅម្តង យើងធ្វើបន្ទាប់ៗ គ្នាដូច្នេះតទៅ លុះត្រាតែព្រះជាម្ចាស់មេត្តាដល់យើង" ។

ព្រះរាជបុត្រទាំងបីព្រមទទួលព្រះរាជឱង្ការនៃព្រះបិតា ឥតមានយល់ទាស់ ហើយព្រះរាជបុត្រច្បង ជាបឋម តាប់រៀបប្រដាប់ប្រដានៃដំណើរ ។ ព្រះអង្គម្ចាស់បង ក៏ធ្វើដំណើរចេញទៅ ហើយឈប់សម្រាកព្រះកាយក្នុងរាត្រីមួយនៅក្បែរមាត់ព្រៃមួយដ៏ស្អាតត្រជាក់ ខាងក្រោយដែលបានដើរត្រេច ទឹង ធ្ងន់កាត់ដែនសីមាមាតុភូមិជាយូរអង្វែងថ្ងៃ ។ វេលាដែលព្រះអង្គម្ចាស់អង្គនេះកំពុងតែបង្កាត់ភ្លើងដើម្បីចំអិនព្រះក្រយាស្ងោយ ទ្រង់បានឃើញកញ្ជ្រោងកញ្ចាស់មួយមិនដឹងលេចចេញពីទីណាមកមួយរំពេច រាអង្វរសុំកុំឲ្យទ្រង់លែងព្រួញទៅឲ្យដេញវា ហើយសុំឲ្យទ្រង់មេត្តាប្រទានទំពាំងមួយដុំ ស្រាមួយកែវ ទាំងសុំឲ្យអាណិតនៅជ្រកកំដៅខ្លួនក្បែរភ្លើងផង ។ ព្រះរាជកុមារមិនទទួលធ្វើតាមសេចក្តីអង្វរ បែរជាលែងព្រួញឲ្យទៅដេញកញ្ជ្រោងនោះវិញ ។ ខណៈនោះ សត្វកញ្ជ្រោងធ្វើសញ្ញាមួយស្រាប់តែព្រះរាជកុមារក្លាយខ្លួនទៅជាដុំថ្មភ្នាម ។

ព្រះរាជាដឹងថាព្រះរាជបុត្រច្បងពុំយាងត្រឡប់មកវិញ ទ្រង់បណ្តោយឲ្យព្រះរាជបុត្រទីពីរ ធ្វើដំណើរយាងចេញទៅម្តង ។ ព្រះរាជបុត្រទី២នេះ លុះស្តេចទៅដល់កន្លែងដែលព្រះជេដ្ឋាក្លាយខ្លួនជាថ្ម

កាលណា ទ្រង់ទទួលបាបគ្រោះដូចព្រះរៀមដែរ ដោយហេតុចង់បាន ស្បែកកញ្ជ្រោង ហើយមិនព្រមទទួលយកសេចក្ដីអង្វររបស់ក៏ ។

ព្រះរាជាទ្រង់ព្រួយព្រះរាជហឫទ័យពេក ព្រោះទ្រង់ឃើញកាលវេលាចេះតែកន្លងទៅ ហើយមិនឃើញកូនណាមួយបានបក្សីទិព្វត្រឡប់មកវិញ ។

ថ្ងៃមួយ ព្រះរាជបុត្រពៅក្រាបបង្គំទូលព្រះរាជបិតាថា: " បពិត្រព្រះអង្គដ៏ទ្រង់យស ! ព្រះរៀមទាំងពីរព្រះអង្គ ស្ដេចយាងចេញទៅស្វែងរកបក្សីទិព្វកន្លងមកអស់កាលជាយូរឆ្នាំហើយ ឥឡូវពុំឃើញស្ដេចយាងត្រឡប់មកវិញសោះ មិនដឹងជាព្រះជេដ្ឋាបានសេចក្ដីសុខទុក្ខយ៉ាងណា ; បើដូច្នេះ សូមព្រះអង្គទ្រង់ព្រះមេត្ដាប្រោស ប្រទានប្រាក់ដល់ទូលព្រះបង្គំៗ នឹងយកទៅទិញប្រដាប់ប្រដា នឹងធ្វើដំណើរចេញទៅស្វែងរកម្ដង ដើម្បីជ្រាបព្រេងវាសនាមើល បើទូលព្រះបង្គំចេញទៅស្វែងហើយរកបាន នោះព្រះអង្គសមនឹងមានព្រះហឫទ័យរីករាយដោយហេតុតែបំណងរបស់ព្រះអង្គបានសម្រេច ; បើព្រះអង្គមិនព្រមអនុញ្ញាតទេ, ទូលព្រះបង្គំនឹងមានកេរ្ដិ៍ឈ្មោះមិនប្រសើរឡើយ " ។

ព្រះរាជាមានបន្ទូលតបមកវិញថា: " ម្នាលបា ! ព្រះរៀមរបស់អ្នកមិនទាន់ឃើញត្រឡប់មកវិញ ប្រហែលអ្នកទាំងពីរនោះដល់នូវសេចក្ដីវិនាសរៀងខ្លួន ដោយការចំប្រឹងរកបក្សីទិព្វដ៏អស្ចារ្យ, ឯងឃើញឬទេ ?

គេទៅអស់អំឡុងយូរណាស់ហើយ ។ មិនឃើញអ្នកណាមួយត្រឡប់មកវិញសោះ! ឥឡូវបិតាចាស់ហើយ, បើបាឯងចេញទៅទៀត តើនរណានឹងនៅជួយចាត់ចែងការរាជការក្នុងព្រះនគរ! បើប្រសិនបិតាទិវង្គតទៅ តើអ្នកណានឹងគ្រងរាជ្យស្នងបិតា, ម្នាលកូនសម្លាញ់បិតា! ណ្ហើយចូរនៅក្នុងព្រះនគរហើយ កុំចេញទៅអី” ។

ព្រះរាជបុត្រពោលទូលស្នងវិញថា: “បពិត្រព្រះរាជបិតាដ៏ជាកំពូលកត! ព្រះអង្គតែងទ្រង់ត្រាស់មកហើយថា: ទូលព្រះបង្គំមិនដែលធ្វើអ្វីជាបទដំឆាស់ឲ្យឃ្លាតចាកព្រះរាជឱង្ការទេ បុះហេតុអ្វីថ្ងៃនេះ ទូលព្រះបង្គំទទូចសុំ គឺថាទូលព្រះបង្គំមានបំណងនឹងបំពេញកិច្ចព្រះអង្គ ដោយអានុភាពនៃទូលព្រះបង្គំ តាមព្រះរាជបំណងដែលចេះតែធ្វើដួងព្រលឹងព្រះអង្គមិនឲ្យនៅសុខសម្រាន្ត ហើយដែលតាំងពីប៉ុន្មានឆ្នាំមកហើយ ទ្រង់បានចំណាយអស់ទ្រព្យជាច្រើន ឥតប្រយោជន៍ ។

ដោយសេចក្ដីអង្វរនឹងការទទូចសុំខ្លាំងពេក ព្រះរាជាក៏ទ្រង់យល់ព្រមបើកឲ្យទៅ ។ ព្រះអនុជពោលយកសេះយ៉ាងចំណាននឹងថ្លៃមួយទៅផងធ្វើជាគូកន យកស្បៀងយ៉ាងបរិបូណ៌ ហើយទ្រង់ធ្វើដំណើរចេញទៅ ។

លុះកាលកន្លងទៅមិនយូរប៉ុន្មាន ព្រះរាជបុត្រច្បងទាំងពីរក៏យាងត្រឡប់មកវិញ បាននាំបក្សីទិព្វមក ព្រមទាំងស្ត្រីម្នាក់មកផង ដែលគេ

ទុកឲ្យនៅធ្វើជាអ្នកបោសវត្តអារាមរហូតទៅ ។ ប្រជារាស្ត្រគ្រប់គ្នាតែងស្ងើចសរសើរនូវលំអនៃបល្ល័ង្កដែលមានពណ៌មួយកាន់មួយនៅក្នុងពេមស្វាប ហើយក៏តាំងផ្ទេកៗ ដូចជាកញ្ចក់ឆ្លុះមុខចាំងត្រចៃ ; ចំណែកកំពូលព្រះវិហារក៏លែងបាក់ធ្លាក់ចុះមកក្រោម សត្វបក្សីទិព្វ ធ្វើសំបុកនៅលើកំពូលវិហារនោះ ។ ប៉ុន្តែមិនយូរប៉ុន្មាន គេសំគាល់ឃើញថា សត្វបក្សីនោះហាក់ដូចជាសត្វគ គឺវាគមិនដែលពុសំឡេងសោះ ឃើញល្អតែពេមស្វាប ត្រង់សំឡេងពីរោះគ្មានទេ ។ អ្នកណាដែលបានឃើញបក្សីនោះតែងតែព្រួយធ្ងន់អំពីការអាក់អន់នោះ, សូម្បីព្រះរាជាឯង ទោះបីមានព្រះហឫទ័យរីករាយដោយទតឃើញកំពូលនៃព្រះវិហារបានសង់ហើយស្រេចក៏នៅព្រួយព្រះហឫទ័យត្រង់មិនបានព្រះសណ្ដាប់នូវសំឡេងរបស់បក្សីទិព្វ ។

អ្នកស្រុក អ្នកនគរទាំងឡាយ សប្បាយរីករាយដោយការគេបានបក្សីទិព្វ ទាំងឃើញព្រះវិហារកសាងហើយ ក៏ភ្លេចគិតដល់ព្រះអាណុជនៅ ។ ចំណែកព្រះរាជា ទ្រង់មិនភ្លេចព្រះរាជបុត្ររបស់ព្រះអង្គសោះ ទ្រង់មានព្រះហឫទ័យព្រួយតែមួយព្រះអង្គឯងយ៉ាងស្ងាត់ ព្រោះបាត់ពុំឃើញព្រះរាជបុត្រនោះត្រឡប់មកវិញ ដើម្បីនឹងបានចែកសេចក្ដីរីករាយគ្នា ។

(មានត)

ពន្លឺអាស៊ី

La Lumières de l'Asie

# លោកស៊ីរ-អេតវិនអារណុលដ៍ តែង

លោកកាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(១៥៣)

---

ព្រះពោធិសត្វទ្រង់ស្តេចមកដល់ទីក្រុងជាមួយនឹងពួកមេសបាលអ្នកគង្វាលពពែ (bergers) នៅពេលសាយណ្ហសម័យដែលព្រះសុរិយាកំពុងបំភ្លឺរស្មីជាអវសាន ធ្វើឲ្យទឹកស្ទឹងសោណៈ (Sona) មានសម្បុរក្រហមឆ្អៅដូចជាសុវណ្ណពណ៌ ហើយធ្វើឲ្យប្រថពីមានស្រមោលងងឹតដេរដាសពាសពេញវិថី, មាត់ក្លោងទ្វារព្រះរាជវាំងមានទាហានរក្សាព្រះអន្ត យាមល្បាតនៅទីនោះៗ តែទាហានទាំងនោះដល់ឃើញព្រះពោធិសត្វបីកូនចៀមដូច្នោះ ក៏ថយចេញដោយគោរព, ពួកប្រជាជនដែលនៅផ្សារបានរៀបចំយានជំនិះជាផ្លូវហែនៅតាមពាណិជ្ជដ្ឋាន, ពួកអ្នកលក់នឹងអ្នកទិញឈប់តថ្លៃទំនិញ ហើយក្រឡេកមើលព្រះភក្ត្រព្រះពោធិសត្វដែលមានតេជានុភាពគួរគោរព, ពួកអយការ "ជាងដែក" (forgeron) ដែលកាន់ញញួរនៅដៃលើកឡើងទៅជាស្រឡាំងកាំងឈប់វាយដែក, អ្នកត្បាញសំពត់លះបង់ចោលសរសៃអំបោះ, អ្នកបារ (សរសេរ) សាស្ត្រាបោះបង់ចោលក្រដាស, អ្នកដូររូបិយវត្ថុយកកម្រៃឈប់គិតគណនាខាង

ចំណេញប្អូនភាគ, គោឧសភកដសសុទ្ធនៃព្រះសិរី: បរិភោគស្រូវដែលគ្មានអ្នកណាមើលថែទាំ, ប្ដូរប្ដាន់ដែលដាក់ទឹកដោះគោរលំកំពប់ហូរទឹកដោះគោចេញអស់, ឯអ្នកលក់ទឹកដោះគោបានតែទៅមើលព្រះពោធិសត្វកំពុងត្រេចតាមផ្លូវថ្នល់ ដែលមានព្រះចរិយាស្រគត់ស្រគំ ហើយមានព្រះដំណើរគួរឲ្យគោរពគួរឲ្យកោតក្រែង ។ មានពួកស្ត្រីប្រជុំគ្នានៅមាត់ទ្វារសួរគ្នាថា “អ្នកនេះជាអ្វី? ដែលមកធ្វើពលីកម្មដោយមានចិត្តគួរជាទីទស្សនារម្មណ៍ពន់ពេក ហើយកាលត្រេចទៅទីណា មានមនោគតិផ្សាយជុំវិញ នូវសេចក្ដីសុខសប្បាយស្រួលម៉្លេះ, តើអ្នកនេះចូលក្នុងវណ្ណៈអ្វី? ហេតុម្ដេចចក្ខុឆ្ងាយអ្វីម៉្លេះ? ប្រហែលជាពួកសក្រៈ(១) ឬជាទេវរាជ?” ។ នាងខ្លះតបថា “នេះជាសេខបុគ្គលដែលនៅជាមួយនឹងពួកឥសីលើភ្នំ” ។ ចំណែកព្រះពោធិសត្វទ្រង់យាងផុតទីនោះ ដោយមានព្រះទ័យចុះស្ងប់ទៅក្នុងសមាធិ ហើយព្រះអង្គទ្រង់ពិចារណាក្នុងព្រះទ័យថា “ចចៀមរបស់អាត្មាអញ បន្តិចទៀតគ្មាននាយមេសបាលថែរក្សាទេ, ចៀមទាំងនោះធ្វើដំណើរទៅក្នុងវេលាយប់នេះគ្មានមគ្គទេសក៏ទេ ហើយនឹងស្រែកយំក្ដុង ៗ ដើរចូលទៅជិតកាំបិតនៃស្ដេច

---

១ សក្រៈ បើតាមភាសាមគធៈថា សក្កៈ ឬសក្យ. “ព្រះឥន្ទ្រឬអមនុស្ស” ។

២ ទេវរាជ: ស្ដេចនៃទេវតា ។

មច្ចុរាជ ដូចជាមនុស្សនឹងសត្វតិរច្ឆានដែលឈរឥតនិយាយស្តីនៅទីនេះ ដែលជាបងប្អូនញាតិនឹងគ្នាដូចនោះ" ។

ខណៈនោះ មានមនុស្សម្នាក់ចូលទៅក្រាបបង្គំសួរព្រះមហាក្សត្រិយ៍ ថា "មានលោកសង្ឃពុទ្ធគ្គមួយអង្គនិមន្តមកដល់ទីនេះ បាននាំហ្វូងចៀម ដែលព្រះអង្គមានព្រះឱង្ការ ដើម្បីនឹងយកមកធ្វើពលិកម្ម" ។

ព្រះមហាក្សត្រិយ៍ទ្រង់គង់នៅកន្លែងដែលធ្វើមហាយញ្ញ, ពួកព្រាហ្មណ៍ស្លៀកពាក់អាវវែងពណ៌សឈរអមព្រះអង្គ សូត្រធម៌ "មន្ត្រា" (man-tras) ហើយដុតភ្លើងឲ្យឆេះនូវបូជនិយដ្ឋាន, កណ្តាលកន្លែងនោះ អណ្តាតភ្លើងឆាបឆេះចេញពីឈើក្រអូបឮសូរស័ព្ទដូចគេហួច ហើយពត់ពេនបត់បែនដូចជាគេលិទ្ធដង្ហាយបូជាមានខ្លាញ់ គ្រឿងអលង្ការផ្សេងៗ នឹងព្រះទឹកៈសូមា" (១) ដែលព្រះឥន្ទ្រាធិរាជសព្វព្រះទ័យបំផុត ។ នៅជុំវិញបូជនិយដ្ឋាន, មានទឹកស្ទឹងមានសភាពក្រាស់ៗ មានពណ៌ក្រហមឆ្អៅ មានពពុះផុះឡើងៗ ហូរចូលទៅក្នុងដីខ្សាច់ ហើយមានជានិច្ច; ទឹកនោះគឺជាឈាមសត្វដែលគេយកមកពិឃាតធ្វើពលិកម្មនោះឯង ។

(មានត)

---

១ សូមា (Soma) រុក្ខជាតិនៅក្នុងក្រុម (Asclépiades) ជារុក្ខជាតិមានភេមដុះចេញពីគ្រាប់ ហើយមានទឹកដែលគេយកមកលាយគ្រាប់ធ្វើ នឹងទឹកដោះគោរាប់ថ្ងៃ យកទៅចំរាញ់ធ្វើជាស្រាមួយបែប ស្រានោះគេអុជមានសភាពធ្វើឲ្យស្រវឹងចិត្ត គឺជាស្រាសម្រាប់បូជាព្រះឬទេវតាព្រហ្ម ។

# ព្រះទេពមុនី យូរ - ប៉ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះតថាគតមុនីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

វេលានេះ នឹងស្រង់យកពលធម៌ដែលព្រះសម្ពុទ្ធជាបរមគ្រូយើង សំដែងទុកក្នុងសុត្តន្តបិដក មកអធិប្បាយជាផ្លូវធម៌ខ្លះ ផ្លូវលោកខ្លះ តាមសមគួរដូចតទៅនេះ ៖

មនុស្សគ្រប់ជាតិគ្រប់ភាសា ដែលកើតមកក្នុងលោកនេះ សុទ្ធតែមានកិច្ចការគួរប្រកបគួរប្រតិបត្តិ ដែលជាផ្លូវធម៌ផ្លូវសាសនា ឬក៏ផ្លូវលោក ។ ឯកិច្ចការដែលគួរប្រកបគួរប្រតិបត្តិនោះ មានច្រើនស្ថាន គឺតូចខ្លះ ធំខ្លះ ថោកទាបខ្លះ ឧត្ដមខ្លះ លំបាកខ្លះ ងាយខ្លះ ។ អ្នកប្រកបកិច្ចការគ្រប់ចំពូកនោះ ត្រូវការស្រ័យកំឡាំងជាប្រមុខ, បើមិនមានកំឡាំងហើយពុំអាចនឹងប្រកបកិច្ចការនោះៗ បានឡើយ ។ កំឡាំងនេះជាធម្មជាតិសំខាន់បំផុតក្នុងកិច្ចការគ្រប់យ៉ាង ព្រោះហេតុនោះ

បុគ្គលគួរទំនុកបំរុងរក្សាកំឡាំងកាយឲ្យរឹងប៉ឹង សំរាប់ប្រកបកិច្ចការតាមនាទីរបស់ខ្លួន ។ កំឡាំងកាយជាធម្មជាតិសំខាន់ក៏ពិត ប៉ុន្តែបើមិនបានកំឡាំងចិត្តជួយអមផង កិច្ចការនោះៗ ក៏មិនបានសម្រេចប្រយោជន៍ដ៏ធំទូលាយប៉ុន្មាន ព្រោះកំឡាំងកាយនិងកំឡាំងចិត្តទាំងពីរនេះអាស្រ័យគ្នាខ្វះណាមួយពុំបាន បើមានគ្រប់លក្ខណៈទាំងពីរស្ថិតក្នុងបុគ្គលណាហើយ បុគ្គលនោះទើបមានសមត្ថភាពអាចបំពេញប្រយោជន៍សព្វគ្រប់បាន ។

មួយទៀត ចិត្តនេះបើមិនបានទទួលការអប់រំសេចក្តីល្អទុកទេ ក៏មិនមានគោលអ្វីដ៏សំខាន់ជាគ្រឿងទំនុកបំរុងកងកាយ ឬ ឥស្សរភាពបានឡើយ ។ បុគ្គលដែលនឹងឡើងទៅកាន់ឋានខ្ពស់បាន ក៏ព្រោះអាស្រ័យការអប់រំចិត្តគំនិតឲ្យប្រព្រឹត្តទៅក្នុងផ្លូវល្អ ប្រកបដោយប្រាជ្ញាដឹងច្បាស់រើសរកផ្លូវត្រូវនិងផ្លូវមិនត្រូវ · ឲ្យសមតាមកាលៈទេសៈ; បើបណ្តែតបណ្តោយទៅតាមទំនើងចិត្តហើយ មុខជាសេចក្តីអាក្រក់ទង់ទាញទំលាក់ទៅកាន់ទីថោកទាបពុំខាន ។

បុគ្គលដែលមានចិត្តអប់រំល្អហើយ រមែងនាំសេចក្តីល្អមកដល់ខ្លួនគឺល្អជាងសេចក្តីល្អដែលមាតាបិតាញាតិមិត្របងប្អូនផ្គត់ផ្គង់ឲ្យទៅទៀត ។ បើចិត្តប្រាសចាកសេចក្តីអប់រំហើយក៏រមែងនាំឲ្យកើតសេចក្តីវិនាសផ្សេងៗ ។

មួយវិញទៀត ការដែលនឹងអប់រំចិត្តឲ្យមានកំឡាំងក្លាហានគួរដល់ការងារនោះ ត្រូវអាស្រ័យសេចក្តីអប់រំក្នុងធម៌, ព្រោះធម៌ជាគ្រឿងបង្អុល

ប្រាប់ផ្លូវឲ្យដឹងច្បាស់ ខុសត្រូវ ល្អអាក្រក់ បុណ្យបាប គុណទោស ។ ព្រោះហេតុនោះ ជនអ្នកស្រឡាញ់សេចក្ដីល្អ គួរអប់រំកំលាំងចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមធម៌ ១ ពួក ដែលជាពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធ-សាសនា ហៅថា ពលធម៌ មាននៅក្នុងពួកពោធិបក្ខិយធម៌ (ធម៌កើតមានក្នុងចំណែកនៃការត្រាស់ដឹង ; ទុកជាគ្រឿងអប់រំចិត្តឲ្យមានសមត្ថ-ភាពក្នុងការប្រតិបត្តិ ។ ពលធម៌នោះ មាន ៥ យ៉ាងគឺ : សទ្ធាពល: ១ វីរិយពល: ១ សតិពល: ១ សមាធិពល: ១ បញ្ញាពល: ១ ។

**១ សទ្ធាពល:** ប្រែថា "កំលាំងគឺសទ្ធា" ។ ការប្រតិបត្តិធម៌ជាពាក្យប្រៀនប្រដៅក្នុងព្រះពុទ្ធសាសនា ឬប្រកបកិច្ចការអ្វីមួយជាប្រ-យោជន៍ក្នុងបច្ចុប្បន្ននេះ, ខាងដើមត្រូវមានសទ្ធាជាមូល ។ ពាក្យថាសទ្ធានេះ ជាសំដីដែលមហាជនធ្លាប់ឮដិតត្រចៀកមកហើយ, តែបើទុកជាដូច្នោះ ក៏នៅតែមានពួកជនខ្លះ ពុំទាន់ចូលចិត្តច្បាស់លាស់នៅឡើយ ហេតុនេះ សូមអធិប្បាយពាក្យថា សទ្ធា នេះតទៅ ។ ដូចម្ដេចហៅថា សទ្ធា? សទ្ធា ប្រែថា "ធម្មជាតិមិនរំភើបញាប់ញ័រក្នុងសភាពដែលមិនគួរជឿ" ដូចជឿដោយគេប្រាប់ពន្យល់ថា សេចក្ដីសុខទុក្ខចំរើនវិនាសបានមកពីហេតុខាងក្រៅ មានការបន់ស្រន់បួងសួងទេព្ដាអារ័ក្សអ្នកតាជាដើម ឬជឿដោយសេចក្ដីល្ងង់ ឬក៏កាន់ច្រឡំព្រោះមិនមានប្រាជ្ញាត្រិះរិះឲ្យឃើញហេតុផលជាមុនសិន ហើយកាន់តាមប្រព្រឹត្ត

តាមទៅ, ជឿយ៉ាងនេះមិនហៅថាសទ្ធាក្នុងទីនេះទេ ព្រោះជឿដោយកាន់ច្រឡំ ។ ជនអ្នកមានសទ្ធា មុននឹងធ្វើអ្វីនឹងប្រព្រឹត្តអ្វី គួរពិចារណាឲ្យឃើញហេតុផលជាក់លាក់សិនហើយសឹមជឿ កុំជឿតាលតែស្ដុះស្ដកខកគំនិតទាញមកវិញមិនបាន ។ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា សទ្ធានឹងបញ្ញាជាគូគ្នា បើមានតែសទ្ធាមិនមានបញ្ញា នឹងប្រកាន់ជឿទៅលើខុសពុំបានសម្រេចប្រយោជន៍ ។ សទ្ធាទុកដូចជាពូជ, បញ្ញាទុកដូចជាផែនដី, កាលបើគេយកពូជទៅសាបព្រោះបណ្ដុះដាំលើផែនដីឬក្រួសថ្មដែលជាធម្មជាតិឥតមានដីជាតិ ពូជនោះក៏ពុំអាចនឹងដុះមានពន្លកដើមដងបានឡើយ ព្រោះបណ្ដុះដាំទៅលើធម្មជាតិដែលឥតមានដីជាតិ ។ លុះណាតែយកពូជនោះទៅបណ្ដុះដាំលើផែនដីមានដីជាតិល្អ ទើបពូជនោះនឹងមានពន្លកដុះលូតលាស់ទៅបាន យ៉ាងណាមិញ; សទ្ធាក៏ដូច្នោះដែរ លុះណាតែប្រកបដោយបញ្ញាផង ទើបសទ្ធានោះនឹងមានកំឡាំងមិនងាកបែរបែរទៅរកផ្លូវខុសបាន ។

មួយទៀត សទ្ធាទុកដូចជាទ្រព្យដ៏ប្រសើរ, មានពុទ្ធភាសិតថា

**សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** "សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះ" ។

ទ្រព្យទាំងអស់ក្នុងលោកមានមាសប្រាក់ជាដើម សុទ្ធតែជារបស់តែងមានសេចក្ដីវិនាសអន្តរាយទៅដោយហេតុផ្សេង ៗ មានចោរលួចក្លែង

នេះជាដើម ជាទ្រព្យមិនអាចរក្សាអំណាចបង្ក្រាបបញ្ហារបស់ខ្លួនឡើយ មានតែនាំខ្លួនឲ្យដល់នូវសេចក្ដីវិនាសព្រោយលំបាកជានិច្ច, អ្នកប្រាជ្ញខាងផ្លូវធម៌លោកមិនត្រូវការចង់បាន [illegible] ឡើយ ។

ចំណែកទ្រព្យគឺសទ្ធានេះ [illegible] ជាធម្មជាតិប្រសើរបំផុត ជារបស់មានខ្លឹម មិនពុកផុយរលួយទៅដោយហេតុផ្សេងៗ ទោះចោរក៏លួចយកពុំបាន ជាទ្រព្យជាទីពេញចិត្ត នៃបណ្ឌិត របស់អ្នកប្រាជ្ញ ជាទ្រព្យសម្រាប់ទិញយកអសទ្ធិយធម៌ គឺសេចក្ដីមិនជឿនោះចោលចេញពីសន្ដាន ។

សទ្ធានេះមាន ៤ យ៉ាងគឺ

១ – ជឿកម្ម (កម្មសទ្ធា)

២ – ជឿផលរបស់កម្ម (វិបាកសទ្ធា)

៣ – ជឿថាសត្វមានកម្មជារបស់ខ្លួន (កម្មស្សកតាសទ្ធា)

៤ – ជឿប្រាជ្ញត្រាស់ដឹងព្រះតថាគត (តថាគតពោធិសទ្ធា) ។

កងទីនេះនឹងលើកយកតែសទ្ធាពីរយ៉ាងខាងចុងមកអធិប្បាយ ។

**ជឿថាសត្វមានកម្មជារបស់ខ្លួន** នោះគឺ ជឿថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ៗ សេចក្ដីនេះគប្បីឃើញនូវអំពើរបស់ខ្លួននឹងអ្នកដទៃ ដែលមានអំណោយផលឲ្យឃើញប្រាកដ ដូចជនអ្នកមានសទ្ធាឲ្យនូវវត្ថុអ្វីៗ ដល់គេ ទោះបីជាមិនបានវត្ថុអ្វីជាទីគាប់ចិត្តមកវិញទេ ក៏គង់បានពរស័ព្ទសាធុការអំពីបណ្ដាហាកក្នុងបច្ចុប្បន្ននេះមកវិញដែរ; នេះជា-

បំណែកខាងល្អ ដែលហៅថាកុសលកម្ម ។ បើខាងអាក្រក់វិញ ដូចយ៉ាងមនុស្សប្រព្រឹត្តចោរកម្ម មានលួចប្លន់ឆក់ដណ្តើមយកទ្រព្យគេជាដើម រាជការចាប់យកមកវាយតប់ធាក់ដាក់គុកដាក់ច្រវាក់ ធ្វើតាមទោសដែលខ្លួនប្រព្រឹត្តនេះ, ជាអំពើអាក្រក់ដែលហៅថា អកុសលកម្ម ។ កម្មទាំងពីរយ៉ាងនេះ ជួនកាលឲ្យផលក្នុងបច្ចុប្បន្ននេះភ្លាមៗក៏មាន ជួនកាលឲ្យផលទៅបរលោកក៏មាន; ប៉ុន្តែកម្មទាំងពីរយ៉ាងនេះឲ្យផលមិនស្មើគ្នាទេ ដូចពុទ្ធភាសិតថា:

ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ

"ធម៌ពីរយ៉ាងគឺបុណ្យនិងបាប មានផលមិនស្មើគ្នាទេ បាបរមែងនាំសត្វឲ្យទៅកើតក្នុងនរក បុណ្យរមែងនាំសត្វឲ្យទៅកើតក្នុងសុគតិភព ។

មួយទៀត មានបុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើអំពើល្អក្តីអាក្រក់ក្តី, ប៉ុន្តែអំពើនោះមិនទាន់ឲ្យផល ដោយមានហេតុដទៃមកស្កះបិទបាំងកំបាំង មិនបេញមុខឲ្យឃើញប្រាកដ, ក៏យល់ថាសេចក្តីល្អអាក្រក់មិនឲ្យផល; ម្នោះហើយក៏លែងជឿលែងធ្វើលែងប្រព្រឹត្តតាមផ្លូវត្រូវទៅវិញក៏មាន; បើតាមសេចក្តីពិត មិនមែនដូច្នោះទេ ព្រោះគង់តែអំពើនោះឲ្យផលពុំខាន; សមដូចពុទ្ធភាសិតថា:

បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ បាបានិ បស្សតិ

"បុគ្គលអ្នកធ្វើនូវអំពើអាក្រក់ រមែងឃើញតែសេចក្តីចំរើន កំណត់ត្រឹមពេលដែលបាបមិនទាន់ឲ្យផល, លុះដល់ពេលណាបាបឲ្យផល គេទើបចួបប្រទះនូវបាបទាំងឡាយក្នុងពេលនោះ" ។

ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ ភទ្រានិ បស្សតិ

"បុគ្គលអ្នកធ្វើនូវសេចក្តីល្អ ចួបប្រទះតែសេចក្តីអាក្រក់ កំណត់ត្រឹមពេលដែលសេចក្តីល្អមិនទាន់ឲ្យផល, លុះដល់ពេលណាសេចក្តីល្អឲ្យផល គេទើបចួបប្រទះនូវសេចក្តីសុខក្នុងពេលនោះ" ។

ពុទ្ធភាសិតនេះ បំភ្លឺឲ្យឃើញថា អំពើល្អក្តីអាក្រក់ក្តី ដែលបុគ្គលធ្វើហើយ ចួនកាលឲ្យផលភ្លាមៗ ចួនកាលក៏ពុំទាន់ឲ្យផល ដោយមានហេតុដទៃមកស្ទះបាំងខ្ទប់មិនចេញមុខឲ្យឃើញប្រាកដ ; ប៉ុន្តែមុខជានឹងមានឱកាសណាមួយនឹងឲ្យផលពុំខាន ។

មានពុទ្ធភាសិតមួយបែបទៀតថា សកេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ

"សព្វសត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទ្រព្យសំបាច់ ឬជាមតិក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹងអាស្រ័យ ទោះសត្វទាំងនោះធ្វើកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី ត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ" ។

ព្រោះហេតុនោះ ជនអ្នកមានសទ្ធាគួរមានសេចក្តីជឿថា សេចក្តីល្អអាក្រក់បានមកពីហេតុ គឺអំពើដែលខ្លួនធ្វើ ធ្វើយ៉ាងណា ត្រូវទទួលអំណាយផលយ៉ាងនោះ មិនខុសពីដំណើរអំពើដើម ; យ៉ាងនេះហៅថា "ជឿថាសត្វមានកម្មជារបស់ខ្លួន" ។

**ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគតនោះ គឺៈ** សទ្ធាដែលជឿនូវការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ថា ព្រះពុទ្ធជាម្ចាស់បានត្រាស់ឡើងក្នុងលោកនេះ ទ្រង់មានប្រាជ្ញាជាអស្ចារ្យជាងមនុស្សសាមញ្ញ រកបុគ្គលណាស្មើគ្មាន, ព្រះអង្គឆ្ងាយចាកកិលេសហើយ, ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ចំពោះព្រះអង្គ, ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ, ព្រះអង្គមានដំណើរល្អ, ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក, ព្រះអង្គប្រសើរដោយគុណមានសីលជាដើម, ព្រះអង្គជានាយសារថីទូន្មាននូវបុរសដែលគួរទូន្មាន, ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ, ព្រះអង្គត្រាស់ដឹងនូវអរិយសច្ច ៤ ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង, ព្រះអង្គមិនត្រឡប់កើតក្នុងភពថ្មីទៀត, ធម៌ឯណាដែលមានប្រាកដឡើងហើយ ធម៌នោះមិនកំបាំងនឹងញាណរបស់ព្រះអង្គឡើយ, ធម៌មានត្រឹម

ណា ប្រាជ្ញាញាណក៏ហួស [illegible] ពេកណោះ, ព្រះអង្គមិនខ្វះប្រាជ្ញាត្រាស់ដឹងនូវធម៌ទាំងពួងទៀយ ។ [illegible] បព្ពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយបដិសម្ភិទាមគ្គថា ៖ យាវតកំ ញេយ្យំ. តាវតក ញាណំ, យាវតកំ ញាណំ, តាវតកំ ញេយ្យំ, ញេយ្យ បរិយន្តិកំ ញាណំ, ញាណបរិយន្តិកំ ញេយ្យំ "ធម៌ដែលព្រះសព្វញ្ញុពុទ្ធគប្បីជ្រាបត្រឹមណា ប្រាជ្ញាញាណក៏មានត្រឹមណោះ, ប្រាជ្ញាញាណមានត្រឹមណា ធម៌ដែលព្រះអង្គគប្បីជ្រាបក៏មានត្រឹមណោះ, ប្រាជ្ញាញាណមានត្រឹមទីបំផុតនៃធម៌ដែលព្រះអង្គគប្បីជ្រាប ធម៌ដែលព្រះអង្គគប្បីជ្រាបមានត្រឹមទីបំផុតនៃប្រាជ្ញាញាណ គឺថាធម៌ទាំងប្រាជ្ញាញាណមិនលើសមិនខ្វះគ្នា" ។

ការត្រាស់ដឹងរបស់ព្រះសព្វញ្ញុពុទ្ធនេះ ជាអស្ចារ្យប្លែកជាងមនុស្សសាមញ្ញ, កាលបើត្រាស់ដឹងធម៌ណាហើយ ធម៌នោះជាធម៌ពិតធម៌មែន ហើយព្រះអង្គមិនលាក់ទុកដឹងតែមួយព្រះអង្គឯង ទ្រង់សំដែងពន្យល់ដល់សព្វសត្វឲ្យប្រតិបត្តិតាម យល់តាមដូចព្រះអង្គដែរ ។

ព្រោះហេតុនោះ យើង [illegible] បាសកជន គួរជឿចំពោះការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ [illegible] មកខាងលើនេះ ហើយកាន់តាមប្រព្រឹត្តតាមពាក្យប្រៀន [illegible] ទ្រង់សំដែងទុកមក ដើម្បីនឹងកសាងកំឡាំងកាយកំឡាំងចិត្ត [illegible] ម្ចាស់; សេចក្តីជឿយ៉ាងនេះហៅថា "ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត" ។ (មាឧក)

ពិធីបុណ្យស្រង់ទឹក

# សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត

សង្ឃនាយក គណៈមហានិកាយ

គឺ

# ព្រះទេពសុត្ថា សួរ-ហាយ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(ត - ចប់)

---

## សុន្ទរកថា

# ព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងសាលាបាលីជាន់ខ្ពស់

---

សូមថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិត,

សូមចំរើនពរលោកកុម្មិសែរដឺឡារេពុយព្លិក,

សូមទូលសម្តេច,

សូមចំរើនពរ ព្រះតេជព្រះគុណ ទូរអស់លោក-អ្នកពុទ្ធបរិស័ទ សប្បុរសទាំងឡាយ!

ក្នុងនាមនៃព្រះសង្ឃគ្រប់គំណែនដីនគ្រប់ឋានៈ, អាត្មាភាពសូមថ្លែងអំណរដ៏លើសលប់ចំពោះព្រះរាជដំណើររបស់ព្រះករុណាជាម្ចាស់

ជីវិត ដែលទ្រង់ស្តេចមកជា [illegible] ធិបតី ព្រមទាំងលោកកុម្មស៊ែរទីង ព្រះតេជព្រះគុណទាំងឡាយ ដែលបានអញ្ជើញមកក្នុងពិធីបុណ្យស្រង់ទឹកសម្តេចព្រះមហាសុមេធាធិបតីនេះ ។

អាត្មាភាពសូមព្រះរាជទានឱកាសថ្លែងប្រវត្តិរបស់សម្តេចព្រះមហាសុមេធាធិបតីថ្វាយជាសេចក្តីសង្ខេបដូចតទៅនេះ ៖

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយអង្គនេះ កើតឆ្នាំវកធស័ក ព.ស. ២៤២៦, គ.ស. ១៨៨៣ ។

កាលនៅជាសាមណេរអាយុ ១៦ ឆ្នាំ បានចេញពីវត្តពោធិព្រឹក្ស (ហៅវត្តពោល្យំ) ឃុំលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជាជាតិភូមិរបស់លោក មកនៅវត្តឧណ្ណាលោម បានរៀនសូត្រព្រះបរិយត្តិធម៌ដោយព្យាយាមយ៉ាងម៉ឺងម៉ាត់ អំពីសំណាក់ម្ចាស់អាចារ្យជាច្រើនរូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងសម័យនោះ ។

លុះបានជន្មាយុ ២១ ឆ្នាំ សម្តេចបានទៅសូមឧបសម្បទាជាភិក្ខុភាវៈ ឯវត្តពោធិព្រឹក្ស ហើយបានត្រឡប់មកកាន់វត្តឧណ្ណាលោមវិញ ។ សម្តេចតែងមានហឫទ័យសប្បាយតែនឹងការរៀនសូត្រ មិនត្រឹមតែភាសាខ្មែរទៀយ សម្តេច[illegible] ភាសាបាលី, ឡាតាំង, សៀម, លាវ, ភូមា, លង្កា ([illegible]) ហើយចេះភាសាសៀមនិងលាវយ៉ាងស្ទាត់ ព្រមទាំងចេះភាសាបារាំងល្មមសរសេរបានចរចាបានខ្លះ ។

កាលពីក្នុង ព.ស. ២៤៥៦ (គ.ស. ១៩១៣) សម្តេចបានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថរតនារាម (វិហារព្រះកែវមរកតក្រុងភ្នំពេញ) បាន ៤ ប្រយោគ ដែលជាប្រយោគផុតថ្នាក់ក្នុងសម័យនោះ ។ នៅ គ.ស. ១៩១៥ សម្តេចបានប្រឡងជាប់បានទទួលនាទីជាសាស្ត្រាចារ្យ នៅសាលាបាលីជាន់ខ្ពស់, បានធ្វើជាក្រុមជំនុំតែងវចនានុក្រមខ្មែរ បានបង្ហើយការនោះតែ ១ អង្គលោកដរាបដល់ចប់ ។ ការនេះជាស្នាព្រះហស្តមួយយ៉ាងឯក ។ សម្តេចបានរៀបរៀងសៀវភៅកច្ចាយនូបត្ថម្ភកៈ វេយ្យាករណ៍បាលី, សៀវភៅគិហិបតិបត្តិ, សាមណេរវិន័យ, ភិក្ខុប្បាតិមោក្ខសង្ខេប និងសៀវភៅកាយរង់ខ្លះទៀតជាច្រើន ។

កាលពីក្នុង ព.ស. ២៤៦៥ - ២៤៦៦ (គ.ស. ១៩២២ - ១៩២៣) រាជការបានចាត់សម្តេចឲ្យទៅនៅក្រុងហាណូយ ជាមួយនឹងអាត្មាភាព បានរៀនភាសាសំស្ក្រឹត, អក្សរទេវនាគរី, អក្សរថ្មបុរាណ និងពង្សាវតារព្រះពុទ្ធសាសនាក្នុងនានាប្រទេស ក្នុងសំណាក់អ្នកប្រាជ្ញបារាំងជាច្រើនរូប មានលោកល្វីហ្វីណូត៍ដែលជាចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសក្នុងពេលនោះជាដើម ។

សម្តេចបាននិមន្តទៅកាន់ប្រទេសលាវ ២ ដង, ទៅកាន់ប្រទេសកូស័ងស៊ីនម្តង ជាតំណាងពុទ្ធសាសនបណ្ឌិត្យនិងសាលាបាលីជាន់ខ្ពស់ ក្នុងការជួយបំពេញកិច្ចសម្រាប់ព្រះពុទ្ធសាសនានិងការសិក្សា ។

សម្តេចបានធ្វើជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ពី គ. ស. ១៩៣០, បានឡើងទៅជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ពី គ. ស. ១៩៤៦, បានទទួលធ្វើជាចៅអធិការវត្តឧណ្ណាលោមនេះពី គ.ស. ១៩៤៣, បានទទួលនាទីជាអធិបតីបេរសកាក្នុង គ. ស. ១៩៤៥ បានធ្វើជាអនុប្រធានគណៈកម្មការប្រជុំក្នុង គ. ស. ១៩៤៧ ។ មិនត្រឹមតែកិច្ចការដែលជានាទីរបស់សម្តេចប៉ុណ្ណោះឡើយ ទោះបីអស់លោកមន្ត្រីធំ-តូចក្នុងក្រសួង ក្នុងក្រុមនានា ដែលត្រូវការសាកសួរឬសុំឲ្យជួយស្រាវជ្រាវរកពាក្យពេចន៍ដែលជ្រៅ ដែលកំបាំងជាដើម សម្តេចក៏ឥតមានធុញទ្រាន់ឡើយ សម្តេចបានទទួលការៈធ្វើជាក្រុមជំនុំខាងអក្សរសាស្ត្រនឹងជាមេប្រយោគប្រឡងក្នុងក្រសួងសិក្សាធិការជាច្រើនឆ្នាំ ។

ព្រះករុណាជាម្ចាស់ជីវិតទ្រង់រាជការប្រាកំងបានប្រគេនគ្រឿងឥស្សរិយយសតាមសម័យនិយមដែលសាកលលោកប្រកាន់ គ្រឿងឥស្សរិយយសនោះដូចតទៅនេះ ៖

សម្តេចបានទទួលមេដាយមុនីសារាភរណៈប្រទេសកម្ពុជានៅ គ.ស. ១៩១៧ មេដាយអស្សប្បុទ្ធប្រទេសកម្ពុជា នឹងមេដាយអស្សប្បុទ្ធដ៏រ.១ លានឆត្រស នៃក្រុងលួងព្រះបាង (ប្រទេសលាវ) នៅ គ.ស. ១៩៣៦ មេដាយសេនានៃបណ្ឌិតសភាប្រទេសបារាំង (Officier de l'Académie) នៅ គ. ស. ១៩៣៧ មេដាយអស្សប្បុទ្ធ (Chevalier) ដឺឡាឡេស្យុង

ដូណ្ណឺវ៉ៃប្រទេសបារាំងនៅ គ. ស. ១៩២៣, មេដាយសេនានៃប្រទេសកម្ពុជានៅគ. ស. ១៩៤៤, មេដាយសេនា (Officier) ដឺឡាឡេស្យុងដូណ្ណឺវ៉ៃប្រទេសបារាំងនៅ គ ស. ១៩៤៨ ។

ឯបំណែកខាងសមណសក្តិសម្រាប់ក្រសួងសង្ឃ ក៏សម្តេចបានទទួលបានឡើងជាលំដាប់គឺ:

សម្តេចបានទទួលធ្វើជាបាឡាត់សាក្យបុត្តិយ៍ (បាឡាត់របស់ព្រះសាក្យវង្ស នុត) នៅ គ. ស. ១៩១០ បានឡើងជាព្រះគ្រូសង្ឃសត្ថា (ទីឋានានុក្រមសម្រាប់ឯករបស់សម្តេចព្រះមហាសង្ឃរាជ) ក្នុង គ. ស. ១៩១២ បានឡើងសមណសក្តិជាព្រះសាសនសោភ័ណ (ទីពជាគណៈកិត្តិយស) ក្នុង គ. ស. ១៩៣១ បានឡើងសមណសក្តិជាព្រះពុទ្ធឃោសាចារ្យ (ពជាគណៈថ្នាក់ទី ២ ក្នុងសម័យបច្ចុប្បន្ន) ក្នុង គ. ស. ១៩៤០, បានឡើងសមណសក្តិជាព្រះពោធិវង្ស (ពជាគណៈថ្នាក់ទី ១) ក្នុង គ. ស. ១៩៤៤, ហើយបានឡើងសមណសក្តិជាន់ខ្ពស់បំផុតជាព្រះមហាសុមេធាធិបតី សង្ឃនាយកគ្រប់គ្រងសង្ឃមណ្ឌលខាងគណៈមហានិកាយក្នុងកម្ពុជរដ្ឋនៅ គ. ស. ១៩៤៨ រហូតមកដល់ថ្ងៃអង្គារ ២ កើតខែពិសាខឆ្នាំខាលទោស័ក ព. ស. ២៤៩៣ ត្រូវនឹងថ្ងៃទី ១៨ ខែមេសា ១៩៥០ នេះ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ប្រោសព្រះរាជទានសមណសក្តិឲ្យបានឡើងទីជា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ។

ក៏ឲ្យព្រះភិក្ខុសង្ឃនិងពុទ្ធបរិស័ទទាំងឡាយ មានអំណរដ៏លើស លប់ចំពោះសមណសក្តិក្នុងឆ្នាំ សម្រាប់ព្រះសង្ឃនាយក ដែលព្រះករុណាជាអម្ចាស់ជីវិត ទើបទ្រង់ប្រោសព្រះរាជទាននេះ ដោយយល់ឃើញថា សម្ដេចព្រះសង្ឃនាយកអង្គនេះ ជាព្រះថេរៈអង្គអាចបរិបូណ៌ដោយសមត្ថភាព និងវិរិយភាព អាចគ្រប់គ្រងសង្ឃមណ្ឌលឲ្យមានការលូតលាស់ចំរើនក្នុងព្រះពុទ្ធសាសនាតទៅ ទើបបានព្រមព្រៀងរួបរួមគ្នាឡើង ធ្វើពិធីបុណ្យស្រង់ទឹកជាយសាភិសេកមង្គលប្រគេនសម្ដេច ដោយព្រះករុណាជាអម្ចាស់ជីវិតទ្រង់ប្រោសព្រះរាជទាន ព្រះរាជានុញ្ញាតផង ។

បុណ្យកុសលនេះ មានព្រះករុណាជាអម្ចាស់ជីវិតជាប្រមុខ, អាត្មាភាពជាតំណាងពុទ្ធបរិស័ទទាំងអស់ ដែលបានព្រមព្រៀងចាត់ការបុណ្យនេះ សូមធ្វើសត្យាធិដ្ឋានយកកុសលនេះមកប្រតិស្ឋាន សូមឲ្យសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក បានប្រកបដោយសុភមង្គលសុខចំរើនទីឃាយុយឺន! ដើម្បីគ្រប់គ្រងសង្ឃមណ្ឌលក្នុងកម្ពុជរដ្ឋ ឲ្យអស់ពុទ្ធបរិស័ទ ឧបាសកឧបាសិកា ឲ្យបានលូតលាស់ចំរើនក្នុងព្រះពុទ្ធសាសនាអស់កាលជាអង្វែងទៅ ! ។

ទីបំផុតនេះ, អាត្មាភាពសូមឧទ្ទិសផលដែលកើតឡើងអំពីការបុណ្យនេះថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិត សូមទ្រង់ឋិតនៅក្នុងសិរីរាជសម្បត្តិអស់កាលជាអង្វែង ! សូមទ្រង់ប្រកបដោយព្រះជន្មាយុយឺនយូរព្រមទាំងប្រកបដោយសិរីសួស្តិមង្គលគ្រប់ប្រការទៅ ! ។

ជូនចំពោះលោកកុម្មីស្សែរដើឡារេពុយព្លិក, ថ្វាយទ្រង់, ជូនអស់លោក អ្នកទាំងឡាយ សូមឲ្យបានស្ថិតនៅក្នុងសុខ - ចំរើនអស់កាលជាអង្វែងតទៅ ! ។

## សុន្ទរកថា

# របស់សម្ដេច ព្រះមហាសុមេធាធិបតី ជួន - ណាត
# សង្ឃនាយក គណៈមហានិកាយ

---

ថ្វាយព្រះពរ ព្រះករុណា ជាម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

កាលពីថ្ងៃទី ៤ មីនា គ.ស. ១៩៤៨ ព្រះករុណា ជាម្ចាស់ជីវិត បានទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន សមណស័ក្ដិជាព្រះមហាសុមេធាធិបតីសង្ឃនាយកដល់អាត្មាភាព ។ កន្លងមកមិនយូរប៉ុន្មាន ទើបនឹងបានចំនួន ២ ឆ្នាំប៉ុណ្ណោះ ព្រះករុណា ជាម្ចាស់ជីវិត ទ្រង់សព្វព្រះរាជហឫទ័យនឹងបំពេញព្រះរាជករណីយកិច្ច តាមលំអាននៃរដ្ឋប្បវេណី ពីបូរាណកាលរៀងមក ទ្រង់បានឡាយព្រះរាជក្រឹត្យចុះថ្ងៃទី ១៨ មេសា ១៩៥០ ប្រោសព្រះរាជទានសមណស័ក្ដិថ្នាក់ខ្ពស់នេះដល់អាត្មាភាព ឲ្យបានឡើងទីជា "សម្ដេច" មិនតែប៉ុណ្ណោះ លុះដល់មកថ្ងៃនេះ ដែលសន្មតថាជាខួបលក្ខិតសម័យសុភមង្គលដ៏ឧត្ដម, ព្រះករុណាជាម្ចាស់ជីវិត ទ្រង់លះព្រះរាជកិច្ចឈ្មៀតស្ដេចមកផ្ទាល់ព្រះអង្គជាព្រះរាជាធិបតី, ទ្រង់

ព្រះមេត្តាប្រោសព្រះរាជទានដល់អាត្មាភាពទៀត , ដោយមានលោក
កុម្មីស្សែរដឺឡារេពុយព្លិកនៃប្រទេសបារាំង ព្រមទាំងអស់លោករដ្ឋ-
មន្ត្រី និងអស់លោកទីប្រឹក្សាព្រះរាជអាណាចក្រជាដើម បានអញ្ជើញមក
អបអរគោរពព្រះអង្គផង, តាមរបៀបផ្លូវការ; អាត្មាភាពសូមទទួលព្រះ
ពរដ៏ប្រសើរ ដែលព្រះករុណាជាម្ចាស់ជីវិត ទ្រង់ព្រះមេត្តាព្រះរាជទាន,
ដោយអាត្មាភាពមានមនោសញ្ចេតនាត្រេកអរជាអនេក ចំពោះព្រះគុណ
ដ៏ខ្ពង់ខ្ពស់នេះ ៗ ព្រះរាជករណីយកិច្ចនេះ អាចជ្រួតជ្រាបជិតជាប់នៅក្នុង
ដួងចិត្តនៃអាត្មាភាព និងពួកពុទ្ធបរិសទ្យក្នុងព្រះរាជអាណាចក្រកម្ពុជា
បីដូចជាស្នាមនៃព្រះវលញ្ជករគឺត្រាសម្រាប់ផែនដីដែលប្រថាប់ជិតជាប់
លើផ្ទៃក្រដាសដ៏ក្រាស់មិនរលុបរលាយ ជាទីរឭកនឹកឃើញឥតមានភ្លេចៗ
អាត្មាភាពនឹងទទួលភារៈបំពេញករណីយកិច្ច ដែលជានាទីសម្រាប់ព្រះ
សង្ឃនាយក បំរើព្រះពុទ្ធសាសនាដោយសភាពជាពុទ្ធទាសៈ ឬជាពុទ្ធ-
លេខាធិការ ដោយមានព្រះករុណាជាម្ចាស់ជីវិតជាអគ្គសាសនូបត្ថម្ភកៈ
ជាទីពឹងពំនាក់ដ៏ខ្ពង់ខ្ពស់របស់ប្រជានិករ ជាពុទ្ធមាមកជនក្នុងកម្ពុជរដ្ឋទាំង
មូល ៗ ការទទួលភារៈបំពេញករណីយកិច្ច ដោយយកចិត្តទុកដាក់ពុំហ៊ាន
ប្រហែសធ្វេសនោះ ជាកិច្ចតបស្នងព្រះបរគុណនៃព្រះករុណាជាម្ចាស់
ជីវិត ដែលអាត្មាភាពត្រូវបំពេញ, ត្រូវប្រតិបត្តិ តាមសមគួរដល់ថាមពល
និងសមត្ថភាព និងគោះគើយព្រងើយពុំបាន និងខានក៏ពុំកើត ដោយ

អាត្មាភាពមានសេចក្ដីគោរព ចំពោះព្រះពុទ្ធសាសនានឹងព្រះករុណាជាម្ចាស់ជីវិតជាព្រះប្រមុខមហាក្សត្រិយ៍ ទោះបីក្នុងវេលានេះ អាត្មាភាពមានវ័យចំណាស់ជ្រាលជ្រៅហើយ ក៏នឹងខានគោរព ខានបំពេញករណីយកិច្ចនេះពុំបាន ។

នៅទីបំផុតនេះ អាត្មាភាពសូមលើកយកគុណព្រះរតនត្រ័យនឹងគុណធម៌ដ៏ឧត្ដមមកជាអានុភាព ជាទីតាំងជាជ័យសក្ដិសិទ្ធ, សូមព្រះករុណាជាម្ចាស់ជីវិត នឹងសម្ដេចព្រះបរមរាជបិតា, សម្ដេចព្រះវររាជជននី-នាថ ទ្រង់បានប្រកបដោយសិរីសួស្ដីក្នុងរាជសម្បត្តិវិវឌ្ឍនមង្គល, សូមមានព្រះជន្មវស្សាយឺនយូរអង្វែង !

លោកកុម្ម៉ៃស៊ែរជើងឡាវេតុយពុក, អស់លោករដ្ឋមន្ត្រី, អស់លោកទាំងឡាយដែលបានអញ្ជើញមកក្នុងមហាសន្និបាតអមព្រះអង្គនេះ, ទ្រង់នឹងសម្ដេចទាំង ២ ព្រះអង្គនឹងព្រះភិក្ខុសង្ឃសាមណេរទាំងអស់ សូមតាំងនៅក្នុងវឌ្ឍនធម៌នឹងសីលធម៌គប់ប្រការសព្វទិវារាត្រីរៀងទៅ !

សូមព្រះរាជអាណាចក្រកម្ពុជា បានដល់នូវសន្តិភាពយាងស្រួលទាន់សម័យ កុំបីឃ្លាតឆ្ងាយទៅណាប្រការៈដទៃឡើយ ! ។

សុន្ទរកថា

# របស់ព្រះទេពសត្ថា សូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

ថ្លែងតំណាងនាមព្រះសង្ឃរាជាគណៈ មេគណ អនុគណ និងចៅអធិការ

---

សម្ដេច !

ពេលនេះជាឱកាសល្អ ដែលគួរទៀតសំដែងសេចក្ដីសោមនស្ស ចំពោះសម្ដេចដោយសង្ខេប ។

ខ្ញុំព្រះករុណានៅក្នុងនាមនៃព្រះសង្ឃ សូមថ្លែងសេចក្ដីជ្រះថ្លា, សេចក្ដីត្រេកអរ ចំពោះកិត្តិយសនៃសម្ដេច ជាតំណាងនៃព្រះថេរៈជារាជាគណៈ និងឋានានុក្រម ព្រមទាំងព្រះសង្ឃក្នុងកម្ពុជរដ្ឋទាំងមូល ដូចសេចក្ដីរៀបរាប់តទៅនេះ ៖

ខ្ញុំព្រះករុណាពល់រូបមានសេចក្ដីជ្រះថ្លា ត្រេកអរជាទីបំផុត ចំពោះសម្ដេចដែលបានឡើងឋានៈដ៏ខ្ពង់ខ្ពស់ ដូចបំណងរបស់ខ្ញុំព្រះករុណាទាំងឡាយ ដែលបានទឹកដៅចំពោះជាយូរឆ្នាំមកហើយ: ទាំងលោកចៅអធិការ គ្រូសូត្រ ជាច្រើនវត្តច្រើនរូប តែងមានសំឡេងលាន់មាត់សរសើរដោយពេញចិត្ត ព្រមទាំងទឹកសង្ឃឹមមកជាយូរហើយ ចំពោះសម្ដេច តាំងពីកាលសម្ដេចនៅក្នុងឋានៈជាព្រះគ្រូសង្ឃសត្ថានៅឡើយ នឹកថា « ក្នុងចំណោមបណ្ឌិតជាអ្នកប្រាជ្ញច្រើនអង្គ, . ព្រះថេរៈអង្គនេះមានគុណសម្បត្តិសមគួរតាំងប្រសើរ ជាមេគំនិតនៃពុទ្ធបរិសទ្យក្នុងជួ

ព្រះពុទ្ធសាសនាដោយពិត, ព្រះថេរអង្គនេះដែលបានមកជាប់កំណើត ក្នុងប្រទេសកម្ពុជា, ហើយបានទទួលគេឧបត្ថម្ភ, មានព្យាយាមមុតមាំ, មានប្រាជ្ញាវាងវៃ, បានធ្វើការព្រះពុទ្ធសាសនាឲ្យរុងរឿងដោយឥតខ្លាចហត់នឿយ, បំរើព្រះពុទ្ធសាសនាដោយពេញបរិបូណ៌, ឈ្លាសវៃក្នុងភាសានិងអក្សរសាស្ត្រជាច្រើនមុខ ទាំងសំដែងធម៌ទេសនាក៏មានរបៀបទាន់សម័យពីរោះក្បោះក្បាយជាទីបំផុត; អំណើះតទៅគួរបានឡើងសមណស័ក្តិយ៉ាងខ្ពស់ទើបសមគួរ ។

ខ្ញុំព្រះករុណាទាំងឡាយបេះតែនឹកត្រិះរិះថា "កាលណាទៅហ្ន៎! ទើបព្រះថេរៈអង្គនេះបានទទួលសមណស័ក្តិទីរាជាគណៈ" ។

លំដាប់តមក សម្តេចក៏បេះតែបានឡើងសមណស័ក្តិតគ្រៀនជាដរាបឥតមានឧបសគ្គណាមួយមកជំទាស់ទេ ។ សម្តេចបានឡើងឋានៈជាព្រះសង្ឃនាយកកន្លងមកចំនួន ២ ឆ្នាំ, ដល់មកថ្ងៃអង្គារ ២ កើតខែពិសាខឆ្នាំខាលនេះ ស្រាប់តែព្រះករុណាជាម្ចាស់ជីវិតទ្រង់ព្រះមេត្តាប្រោស ស្តេចមកប្រទានព្រះរាជក្រឹត្យដោយផ្ទាល់ព្រះហស្ត ក្នុងវិហារវត្តឧណ្ណាលោម ប្រោសប្រទានឋានៈជាសម្តេចព្រះមហាសុមេធាធិបតី ពេញទី ដូចសេចក្តីនឹករំពឹងនៃខ្ញុំព្រះករុណាទាំងឡាយពិតមែន ។

ខ្ញុំព្រះករុណាពល់រូបទាំងក្រុងភ្នំពេញទាំងស្រុកក្រៅ ដែលផុះមកដោយឈូសរៀបចំរោងតាំងគុំ ថ្វាយព្រះរតនត្រ័យក្នុងឱកាសពិធី

បុណ្យស្រង់ទឹក ចំរើនព្រះជន្មសម្តេចនេះជាភស្តុតាងនៃសេចក្តីជ្រះថ្លា សា-ទររបស់យើងខ្ញុំព្រះករុណា គ្រប់គ្នា ព្រមទាំងបាននិមន្តព្រះសង្ឃ ៦៩ អង្គ ចំរើនព្រះបរិត្តធម៌ប្រគេនកុសល ប្រគេនរាប់ចំពោះសម្តេច សូមជយ-មង្គលសិរីសួស្តីជូនមានដល់សម្តេច ដោយហេតុថា ខ្ញុំព្រះករុណា ទាំងឡាយ ដែលបានទទួលការសិក្សារៀនសូត្រយល់ច្បាប់ធម៌វិន័យក្នុងព្រះពុទ្ធសាសនាច្បាស់លាស់នេះបាន គឺដោយសារគុណធម៌នៃសម្តេច ។

ខ្ញុំព្រះករុណាកល់រូបសូមបញ្ចេញសេចក្តីត្រេកអរ និងសេចក្តីសរសើរយ៉ាងសង្ខេបដោយឥតលាក់លៀម ។ សម្តេចទុកជាសង្ឃបិតានៃព្រះសង្ឃទាំងអស់, ជាប្រិយមហាថេរនៃពុទ្ធបរិសទ្យ ទាំងបព្វជិតទាំងគ្រហស្ថ, ព្រោះថា សម្តេចដែលបានទទួលកំណើតក្នុងប្រទេសកម្ពុជានេះ មានភ័ព្វដ៏ប្រសើរ, មានជីវិតប្រកបដោយប្រយោជន៍ទាំងផ្លូវលោកទាំងផ្លូវធម៌ ។ សម្តេចរាប់ថាជាបុត្រមួយក្នុងពួកបុត្រនៃព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ដែលមានប្រវត្តិដ៏ល្អ ដោយសម្តេចបានរៀបចំធម៌វិន័យលើកស្ទួយនាព្រះពុទ្ធសាសនា ឲ្យមានរបៀបត្រឹមត្រូវដូចបានឃើញជាភស្តុតាងមកហើយ ។ ខ្ញុំព្រះករុណា ទាំងឡាយនឹកសង្ឃឹមជាមុនទៀតថា "ព្រះពុទ្ធសាសនានឹងចំរើនរុងរឿងថ្កុំថ្កើងតទៅអនាគតពុំខាន" ។

បណ្តាពុទ្ធបរិសទ្យទាំងអស់ សម្តេចទុកជាអគ្គសាសនិកបុរសមួយរូបដែលគួរគោរព, គួរយកតម្រាប់តាម, ជាទីពឹងគ្រោះប្រឹក្សាក្នុងផ្លូវអក្សរ

សាស្ត្រ នឹងច្បាប់ព្រះពុទ្ធសាសនាដោយពិត ៗ ក្នុងពេលនេះ មាន ពុទ្ធបរិសទ្យជាច្រើនកុះករមកជួបជុំក្នុងវត្តនេះ ដើម្បីធ្វើបុណ្យទទួលអំណរ ចំពោះសម្តេច ដែលទើបនឹងបានទទួលសមណស័ក្តិ ដូចបំណងនៃពុទ្ធ-បរិសទ្យ ៗ ការធ្វើបុណ្យកុសលនេះ ជាករណីយកិច្ចនៃពុទ្ធបរិសទ្យ ទាំងបព្វជិតទាំងគ្រហស្ថ ៗ

ក្នុងទីបំផុតនេះ, ខ្ញុំព្រះករុណា ជាតំណាងនាមនៃព្រះសង្ឃទាំងអស់ សូមសម្លឹងសន្ទីងព្រះរតនត្រ័យ, សូមប្រគេនពរចំពោះសម្តេច ដូច សេចក្តីតទៅនេះ ៖

១ — សូមសម្តេចមានព្រះជន្មាយុយឺនយូរអង្វែង !

២ — សូមសម្តេចមានសម្បុរឆវីវណ្ណចាំនៅក្នុងកាយជាប្រក្រតី !

៣ — សូមសម្តេចប្រកបដោយសេចក្តីសុខគ្រប់ប្រការ !

៤ — សូមសម្តេចមានកំឡាំងកាយរឹងប៉ឹងកុំបីមានរោគាពាធ !

៥ — សូមសម្តេចមានបដិភាណ គឺប្រាជ្ញាវាងវៃ ជានិច្ចកាល ចាប់ដើមតាំងអំពីថ្ងៃនេះតរៀងទៅ ! ៗ

អ្នករៀបរៀងពិធីបុណ្យស្រង់ទឹក

ព្រះទេពសត្ថា សូរ-ហាយ

## បញ្ជីរាយនាមលោកអធិការដែលតាំងថ្មី

# របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន - តុក នាមឆាយា ធម្មជោត កើតឆ្នាំ រក អាយុ ៣០ វស្សា ៩ ជាចៅអធិការ វត្តពោធិ៍ទន្ទឹម ឃុំស្វាយរំពា ស្រុករំដួល ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦៩២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង - សួង នាមឆាយា ធម្មលិស្សត្ថេរ កើតឆ្នាំ មមែ អាយុ ៣១ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ទន្ទឹម ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន - ឃិន នាមឆាយា លិស្សត្ថេរ កើតឆ្នាំឆ្លូវ អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សយ - លុយ នាមឆាយា វិរិយប្បញ្ញោ កើតឆ្នាំ ... អាយុ ... វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្តសំណា ឃុំកំពង់ ស្រុកដំក្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កេង - ហេង នាមឆាយា ធម្មសុត្តោ កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៧ ជាចៅអធិការវត្តដំក្រែង ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៥៨ ចុះថ្ងៃពុធ ១ កើតខែចេត្រ ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ តាំងលោកប៉ាង - ញ៉ែម នាមធាយា ពុទ្ធគេរ កើតឆ្នាំខាលអាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រស្តាំវត្តដីក្រង ឃុំកំពង់ ស្រុកដីក្រង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគល់ - ម៉ង នាមធាយា ព្រហ្មកេសរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូភី - សួន នាមធាយា ព្រហ្មសរ កើតឆ្នាំ ខាល អាយុ ៤៨ វស្សា ២២ ជាចៅអធិការវត្ត ល្បើក ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦១ ចុះថ្ងៃអង្គារ ៣ កើតខែអាសាឍ ឆ្នាំជូតឯកស័ក ព. ស. ២៤៩២ តាំងលោកគ្រូ ស - កេ នាមធាយា ពុទ្ធគេរ កើតឆ្នាំជូតអាយុ ២៦ វស្សា ៥ ជាគ្រូសូត្រស្តាំវត្តល្បើក ឃុំកំពង់ ស្រុកដីក្រង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូទួន - សាម នាមធាយា ឥន្ទសីលោ កើតឆ្នាំ ខាល អាយុ ៣៦ វស្សា ១៣ ជាគ្រូសូត្រស្តាំវត្តកណ្តាល ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូយ៉ង មុី នាមធាយា ឥន្ទនាគ កើតឆ្នាំមមី អាយុ ៤៤ វស្សា ១៩ ជាគ្រូសូត្រស្តាំ

វត្តបុប្ផសារាម ឃុំកំពង់ក្រើ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស់-សុខ នាមនាយា ភន្តសុវណ្ណ កើតឆ្នាំ ច អាយុ ៤១ វស្សា ១៩ ជាគ្រូសូត្រឆ្វេងវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សាន-យ៉ាន នាមនាយា នន្ទសិរី កើតឆ្នាំ ឆ្លូវ អាយុ ២៥ វស្សា ៥ ជាចៅអធិការ វត្តស្វាយលើ ឃុំស្វាយលើ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ នូ-សេង នាមនាយា បញ្ញាជោត កើតឆ្នាំ ឆ្លូវ អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ វង់-នុត នាមនាយា ព្រហ្មសរ កើតឆ្នាំវក អាយុ ៣០ វស្សា ៩ ជាចៅអធិការវត្តគោកខ្លុក ឃុំវ័តសៀម ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-ឯម នាមនាយា សុវណ្ណសិរី កើតឆ្នាំឆ្លូវអាយុ ២៥ វស្សា ៤ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៦៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សួរ-ទិត នាមនាយា ធម្មជោត កើតឆ្នាំ មមី អាយុ ៣៦ វស្សា ១១ ជាចៅអធិការ វត្តក្បាលដំរី ឃុំល្វែង ស្រុក ខេត្តដដែល ។ (មានត)

# កែពាក្យខុសក្នុងកម្ពុជសុរិយា

លេខ ៦ ឆ្នាំ ១៩៥០

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| លុះត្រាតែអំណាចនោះ ជាស្នាដៃនៃវិចារណញ្ញាណ ដែលផ្ដួចផ្ដើមពីសំឡេង | លុះត្រាតែអំណាចនោះ ជាស្នាដៃនៃវិចារណញ្ញាណ ប៉ុន្តែអំណាចនោះលះបង់ នូវវិចារណញ្ញាណ ដែលផ្ដួចផ្ដើមពីសំឡេង | ៦០១ | ១៣ |
| Moutar noire | Moutarde noire | ៤៥៣ | ១៣ |